ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANACE

# ក្របខ័ណ្ឌនិម្មាបនកម្ម ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រង គម្រោងវិនិយោគសាធារណៈ

## Digital Ecosystem Architecture Framework for Public Investment Project Management



ឆ្នាំ ២០២៥

# មាតិកា


**មាតិកា** ............................................................ i
**អារម្ភកថា** ............................................................ ii
**ប្រកាស** ............................................................ iv
**បញ្ជីពាក្យកាត់** ............................................................ vii
**បញ្ជីរូបភាព** ............................................................ ix
**បញ្ជីតារាង** ............................................................ x
**ខ្លឹមសារសង្ខេប** ............................................................ 1
**១.សេចក្តីផ្តើម** ............................................................ 3
១.១. បរិការណ៍ និងសនិទានកម្ម ............................................................ 4
១.២. គោលបំណង ............................................................ 4
១.៣. វិសាលភាព ............................................................ 5
១.៤. អត្ថប្រយោជន៍ ............................................................ 5
**២.ស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ** ............................ 6
២.១. ក្របខ័ណ្ឌគោលនយោបាយ និងគតិយុត្ត ............................................................ 7
២.២. តួអង្គពាក់ព័ន្ធ ............................................................ 7
២.៣. វដ្តគម្រោងវិនិយោគសាធារណៈ............................................................ 8
២.៤. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធនឹងគម្រោងវិនិយោគសាធារណៈ ............................ 9
២.៥. បញ្ហាប្រឈមនៃប្រព័ន្ធគ្រប់គ្រងទិន្នន័យ ............................................................ 12
**៣. ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថល**............................................................ 14
៣.១. ចក្ខុវិស័យ និងវិធានការគន្លឹះ ............................................................ 15
៣.២. គោលការណ៍ និងអភិក្រម ............................................................ 16
៣.៣. និម្មាបកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថល ............................................................ 17
៣.៤. ប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃគម្រោងវិនិយោគសាធារណៈ............................................................ 19
៣.៥. តួអង្គនិងតួនាទីនៅក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថល ............................ 21
**៤. ផែនការអនុវត្ត** ............................................................ 24
៤.១. យុទ្ធសាស្ត្រនៃការអនុវត្ត ............................................................ 25
៤.២. ទិសដៅអនុវត្ត ............................................................ 26
៤.៣. ការរៀបចំតម្រូវការថវិកាគាំទ្រ ............................................................ 27
៤.៤. ហានិភ័យ............................................................ 28
៤.៥. យន្តការសម្របសម្រួល តាមដាន និងវាយតម្លៃ............................................................ 29
**៥.សេចក្តីសន្និដ្ឋាន** ............................................................ 30
**៦.ឧបសម្ព័ន្ធ** ............................................................ 32
**ឧបសម្ព័ន្ធទី ១៖ បញ្ជីឯកសារក្របខ័ណ្ឌគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្ត** .......33
**ឧបសម្ព័ន្ធទី ២៖ ក្របខ័ណ្ឌអន្តរប្រតិបត្តិការ** ............................................................34
**ឧបសម្ព័ន្ធទី ៣៖ ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ**............................................................ 37
**ឧបសម្ព័ន្ធទី ៤៖ ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ** ............................40
**ឧបសម្ព័ន្ធទី ៥៖** សេចក្តីសម្រេច ស្តីពី ការបង្កើតក្រុមការងាររៀបចំនិម្មាបនកម្មនិងគម្រោងបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ.....................42

# អារម្ភកថា

ការវិនិយោគសាធារណៈ គឺជាកម្លាំងចលករដ៏សំខាន់មួយក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា តាមរយៈការអនុវត្តគម្រោងវិនិយោគសាធារណៈដែលមានហិរញ្ញប្បទានពីប្រភពផ្សេងៗ ដូចជា ហិរញ្ញប្បទានក្នុងស្រុក, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងហិរញ្ញប្បទានតាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។

ស្ថិតក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ សំដៅពង្រឹងប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ធានាឱ្យបានការវិនិយោគចំទិសដៅអាទិភាព, ការបែងចែកធនធានសាធារណៈប្រកបដោយសមធម៌ ចីរភាព និងបរិយាប័ន្ន។ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើរតួជាទ្វារបាលក្នុងការគ្រប់គ្រង និងត្រួតពិនិត្យវដ្តនៃគម្រោងវិនិយោគសាធារណៈនេះ។ ក្នុងការចូលរួមចំណែកបង្កើនប្រសិទ្ធភាពការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ និងស្របតាមការតម្រង់ទិសពីគោលនយោបាយរដ្ឋាភិបាលឌីជីថល រួមទាំងមានការចង្អុលបង្ហាញនៅក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផង, **ការកសាងប្រព័ន្ធអេកូឡូស៊ីឌីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈឱ្យបានរឹងមាំគឺជាកិច្ចការអាទិភាពមួយ** ដើម្បីពង្រឹងការធ្វើសមាហរណកម្មទិន្នន័យនៃគម្រោងវិនិយោគសាធារណៈរបស់ជាតិជារួម សំដៅផ្តល់មូលដ្ឋានគ្រឹះគ្រប់គ្រាន់សម្រាប់ការវិភាគ និងការសម្រេចចិត្តជាយុទ្ធសាស្ត្រ ក្នុងគោលដៅធានាឱ្យបាននូវការវិនិយោគចំទិសដៅអាទិភាព និងការបែងចែកធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព និងចីរភាព សម្រាប់ការអភិវឌ្ឍជាតិដែលនឹងបម្រើផលប្រយោជន៍ ជូនប្រជាជនកម្ពុជាចំគោលដៅ។

ជាក់ស្តែង, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចបាននូវការកសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើនរួចហើយសម្រាប់គាំទ្រដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប៉ុន្តែការគ្រប់គ្រងទិន្នន័យនៃគម្រោងវិនិយោគសាធារណៈនៅតែបន្តមានបញ្ហាប្រឈម ដូចជា ការបែកខ្ញែកទិន្នន័យគម្រោងវិនិយោគពីប្រភពហិរញ្ញប្បទានផ្សេងគ្នា, ការរាយការណ៍មិនទាន់គ្រប់ជ្រុងជ្រោយ, ភាពស្មុគស្មាញ និងភាពមិនទាន់អាចធ្វើការវិភាគឱ្យបានស៊ីជម្រៅនិងគ្រប់ជ្រុងជ្រោយក្នុងការធានាភាពចំគោលដៅសម្រាប់ការវិនិយោគនៅឡើយ។ ក្នុងន័យនេះ, មុននឹងឈានសម្រេចបានការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលដែលមានភាពរឹងមាំ គឺទាមទារចាំបាច់ឱ្យមានការរៀបចំនូវ **ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ**ឱ្យបានរួចរាល់ជាមុន។ ក្របខ័ណ្ឌនិម្មាបនកម្មនេះ នឹងផ្តល់នូវមគ្គុទេសក៍ គោលការណ៍ និងអភិក្រម សម្រាប់ការធ្វើទំនើបកម្មការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមប្រព័ន្ធ ឌីជីថលទាំងស្រុង ដែលនឹងលើកកម្ពស់ការធ្វើសមាហរណកម្មទិន្នន័យ តាមរយៈការធ្វើសន្ទានកម្ម និងការធ្វើអន្តរប្រតិបត្តិការរវាងប្រព័ន្ធនិងប្រព័ន្ធ ក្នុងប្រព័ន្ធអេកូឡូស៊ីនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ជាពិសេស ប្រព័ន្ធឌីជីថលដែលស្ថិតនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថល សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនេះត្រូវបានគិតគូររៀបចំជាប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ ដែលមានអភិក្រមរក្សានិងពង្រឹងប្រព័ន្ធដែលមានស្រាប់ និងបង្កើតប្រព័ន្ធថ្មីដែលនឹងបំពេញបន្ថែមមុខងារចន្លោះប្រហោង ជាពិសេសប្រព័ន្ធស្នូលកណ្តាលដែលមានតួនាទីជាប្រព័ន្ធសម្របសម្រួល និងជាប្រព័ន្ធធ្វើសមាហរណកម្មទិន្នន័យ ជាមួយនឹងការ-

ពង្រឹងការធ្វើអន្តរប្រតិបត្តិការជាលក្ខណៈប្រព័ន្ធអេកូឡូស៊ីឌីជីថល សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈទាំងមូល។ ខ្ញុំជឿជាក់ថា, ការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មនេះ នឹងសម្រេចបាននូវ ការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថល សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈមួយដ៏មានប្រសិទ្ធភាពចូលរួមចំណែកដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ យ៉ាងណាមិញ, ការអនុវត្តនេះ ទាមទារចាំបាច់នូវការចូលរួម និងការសហការពីគ្រប់តួអង្គពាក់ព័ន្ធ ក្នុងស្មារតីប្រកាន់ខ្ជាប់នូវអភិក្រម ប្រយ័ត្នប្រយែង និងសន្សឹមៗ ឈរលើគោលការណ៍ ប្រាកដនិយម, ទន់ភ្លន់ និងរៀនផង-ធ្វើផង ដែលការអនុវត្តនេះនឹងអាចមានការប៉ះពាល់ដល់ការបំពេញការងារប្រចាំថ្ងៃ ការផ្លាស់ប្តូររបៀបធ្វើការ និងការកែសម្រួលលក្ខខណ្ឌការងារមួយចំនួន។

ក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល រួមទាំងក្រុមការងាររៀបចំនិម្មាបនកម្ម និងគម្រោងបច្ចេកវិទ្យាព័ត៌មាន នៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោង វិនិយោគសាធារណៈ ក្រោមការដឹកនាំរបស់ ឯកឧត្តមបណ្ឌិត **គង់ ម៉ារី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះការ-សម្រេចបាននូវ ឯកសារក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដែលជាឯកសារដ៏មានសារសំខាន់សម្រាប់ការតម្រង់ទិសជាយុទ្ធសាស្ត្រ ក្នុងការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈឱ្យបានរឹងមាំ ចូលរួមចំណែកបង្កើនប្រសិទ្ធភាពសម្រាប់ការវិនិយោគសាធារណៈនៅកម្ពុជា។ ជាមួយគ្នានេះ, ខ្ញុំក៏សូមថ្លែងអំណរគុណ ដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អគ្គនាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធ ដែលបានចូលរួមយ៉ាងសកម្ម និងផ្តល់កិច្ចសហការប្រកបដោយស្មារតីទទួលខុសត្រូវ ក្នុងការរួមចំណែករៀបចំឯកសារខាងលើនេះឱ្យសម្រេចបានជោគជ័យជាស្ថាពរ។

ជាចុងក្រោយ, ខ្ញុំសូមសំណូមពរដល់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ មន្ត្រី បុគ្គលិក នៃក្រសួង-ស្ថាប័នអង្គភាពសាធារណៈប្រហាក់ប្រហែល និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានការ-ពាក់ព័ន្ធទាំងអស់ បន្តចូលរួមប្រកបដោយស្មារតីបុរេសកម្ម និងការទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថល សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈខាងលើនេះ ឱ្យសម្រេចបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់**
**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០១៧ សហវ.ប្រកការ.អតស.ឌ

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេក្វូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការ-ប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ១៦៤ សហវ.ប្រក.អគប ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការវិនិយោគសាធារណៈ
- បានឃើញប្រកាសលេខ ០០៣ សហវ.ប្រក.អហក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំ ស្តីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ
- បានឃើញប្រកាសលេខ ៦១៧ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោង
- បានឃើញប្រកាសលេខ ៧៤៣ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១**.-

ត្រូវបានដាក់ឱ្យអនុវត្ត "**ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ**" ក្នុងគោលបំណងតម្រង់ទិសជាយុទ្ធសាស្ត្រនិងផ្តល់នូវប្លង់និម្មាបនកម្ម សម្រាប់ជាមគ្គុទ្ទេសក៍ក្នុងការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីឌីជីថល សំដៅគាំទ្រដល់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅកម្ពុជា ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព។

**ប្រការ២**.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលរដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល នីតិបុគ្គលដែលទទួលផល-ប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត ដែលបំពេញមុខងារ តួនាទី និងភារកិច្ចពាក់ព័ន្ធនឹងគម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទានស្ថិតនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោងនិងស្ថិតនៅគ្រប់កម្រិតរដ្ឋបាល។


ទំព័រ v

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងប្រធានគ្រប់អង្គភាពឬស្ថាប័នក្រោមអាណាព្យាបាលនិងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់អង្គភាពឬស្ថាប័នក្រោមអាណាព្យាបាល និងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ទំព័រ vi

# បញ្ជីពាក្យកាត់

| | |
|---|---|
| ក.ស.ហ.វ. | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| អ.គ.ប. | អគ្គនាយកដ្ឋានគោលនយោបាយ នៃក.ស.ហ.វ. |
| អ.ប.គ.ហ. | អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក.ស.ហ.វ. |
| អ.រ.ត.ន. | អគ្គនាយកដ្ឋានរតនាគារជាតិ នៃក.ស.ហ.វ. |
| អ.ស.ឌ. | អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក.ស.ហ.វ. |
| អ.ស.ប. | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក.ស.ហ.វ. |
| API | សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ<br>( Application Programming Interface ) |
| BPS | ប្រព័ន្ធរៀបចំផែនការថវិកា<br>( Budget Planning System ) |
| COTS | ផលិតផលក្នុងទីផ្សារពាណិជ្ជកម្មអន្តរជាតិ<br>( Commercial Off-The-Shelf ) |
| CamDX | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា<br>( Cambodia Data Exchange ) |
| CamDigiKey | ថ្នាលគ្រប់គ្រងអត្តសញ្ញាណអតិថិជនឌីជីថល<br>( Cambodia Digital Key ) |
| DI-PIMS | ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគក្នុងស្រុក<br>( Domestic Investment Project Implementation Management System ) |
| DMFAS | ប្រព័ន្ធគ្រប់គ្រងបំណុល និងវិភាគហិរញ្ញវត្ថុ<br>( Debt Management and Financial Analysis System ) |
| FMIS | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>( Financial Management Information System ) |
| GDDE | អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល<br>( General Department of Digital Economy ) |
| GDICDM | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល<br>( General Department of International Cooperation and Debt Management ) |
| GDP | អគ្គនាយកដ្ឋានគោលនយោបាយ<br>( General Department of Policy ) |
| GDPFMIT | អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>( General Department of Public Financial Management Information Technology ) |
| GDPPP | អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន<br>( General Department of Public-Private Partnerships ) |
| GDSNAF | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ<br>( General Department of Sub-National Administration Finance ) |

| | |
|---|---|
| GDSNR | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ<br>( General Department of State Property and Non-Tax Revenue ) |
| i-PIM | ប្រព័ន្ធសមាហរណកម្មទិន្នន័យកណ្តាលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ<br>( Integrated Public Investment Project Management Information System ) |
| JSON | ប្រភេទទម្រង់ទិន្នន័យឌីជីថលដែលជាទូទៅប្រើសម្រាប់ជាមធ្យោបាយផ្លាស់ប្តូរគ្នា<br>( JavaScript Object Notation ) |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>( Ministry of Economy and Finance ) |
| MOP | ក្រសួងផែនការ ( Ministry of Planning ) |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ ( Official Development Assistance ) |
| pID | មូលដ្ឋានទិន្នន័យការអនុវត្តគម្រោងថ្នាក់ក្រោមជាតិ<br>( Sub-National Administration - Project Implementation Database ) |
| PIM | ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ<br>( Public Investment Management ) |
| PIP | កម្មវិធីវិនិយោគសាធារណៈ ( Public Investment Program ) |
| PPDMS | ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោង<br>( Project Portfolio Database Management System ) |
| PIP-DBMS | ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យគម្រោងវិនិយោគសាធារណៈ<br>( Public Investment Project Database Management System ) |
| PFMRP | កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>( Public Financial Management Reform Program ) |
| PPP-PIMS | ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងតាមយន្តការភាពជាដៃគូរវាង រដ្ឋនិងឯកជន<br>( PPP Project Implementation Management System ) |
| SARMIS | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ<br>( State Asset Registry Management Information System ) |
| sPD | មូលដ្ឋានទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>( Sub-National Administration Project Database ) |
| SNA-PIMS | ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងហិរញ្ញប្បទានដោយថវិកាជាតិនៅរដ្ឋបាល ថ្នាក់ក្រោមជាតិ<br>( Sub-National Administration Project Implementation Management System ) |
| XML | ប្រភេទទម្រង់ទិន្នន័យឌីជីថលដែលជាទូទៅប្រើសម្រាប់ជាមធ្យោបាយសម្រាប់ការផ្លាស់ប្តូរ<br>( Extensible Markup Language ) |

# បញ្ជីរូបភាព


**រូបភាព 1** ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ជាតិ ....................5

**រូបភាព 2** ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ....................6

**រូបភាព 3** ការផ្សារភ្ជាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទៅនឹងវដ្តគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ ....................8

**រូបភាព 4** អភិក្រមនៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ....................12

**រូបភាព 5** ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ....................13

**រូបភាព 6** ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ....................14

**រូបភាព 7** ក្របខ័ណ្ឌអន្តរប្រតិបត្តិការ ....................27

# បញ្ជីតារាង


| | |
|---|---|
| **តារាង** 1.<br>ហានិភ័យនៃការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្ម | 22 |
| **តារាង** 2.<br>តារាងចំណាត់ថ្នាក់ទិន្នន័យ | 32 |
| **តារាង** 3.<br>ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ រដ្ឋបាលថ្នាក់ជាតិ | 33 |
| **តារាង** 4.<br>ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ | 34 |

# ខ្លឹមសារសង្ខេប

ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ គឺជាផ្នែកដ៏សំខាន់មួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា, ប៉ុន្តែការគ្រប់គ្រងទិន្នន័យនៃគម្រោងវិនិយោគសាធារណៈនៅជួបប្រទះបញ្ហាប្រឈមនៅឡើយ ដូចជា អសង្គតិភាពនៃទិន្នន័យ, ភាពអាចត្រួតស៊ីគ្នានៃគម្រោង, ភាពយឺតយ៉ាវក្នុងការបូកសរុបទិន្នន័យជាក្របខ័ណ្ឌរួមរបស់ជាតិ, ភាពនៅមានកម្រិតលើការវិភាគទិដ្ឋភាពនៃការវិនិយោគសាធារណៈឱ្យចំគោលដៅ ជាដើម។ ឆ្លើយតបនឹងបញ្ហាប្រឈមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តួចផ្តើមរៀបចំ **ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ** ដើម្បីតម្រង់ទិសជាយុទ្ធសាស្ត្រ និងផ្តល់ជាប្លង់និម្មាបនកម្មគោល ក្នុងការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈឱ្យបានរឹងមាំសម្រេចចក្ខុវិស័យឆ្ពោះទៅរកការគ្រប់គ្រង និងការអនុវត្តគម្រោងវិនិយោគសាធារណៈតាមប្រព័ន្ធឌីជីថលទាំងស្រុង ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការប្រើប្រាស់ថវិកាវិនិយោគឱ្យចំគោលដៅ។

ក្របខ័ណ្ឌនិម្មាបនកម្មនេះ ចែកចេញជាបីផ្នែកធំគឺ ១) ផ្នែកមុខងារប្រព័ន្ធ, ២) ផ្នែកប្រព័ន្ធអេកូឡូស៊ីឌីជីថល និង ៣) ផ្នែកក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ.។ ផ្នែកមុខងារប្រព័ន្ធចែកចេញជាមុខងារស្នូល និងមុខងារគាំទ្រ។ ផ្នែកប្រព័ន្ធអេកូឡូស៊ីឌីជីថល គ្របដណ្តប់លើស្រទាប់ទិន្នន័យនិងស្រទាប់កម្មវិធី ដែលផ្តោតសំខាន់ទៅលើសំណុំនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធអេកូឡូស៊ីសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ ចំណែកឯ ផ្នែកក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ. គឺសំដៅដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងថ្នាលបច្ចេកវិទ្យាព័ត៌មានគ្រឹះដែលមានស្រាប់ និងអនុលោមតាមបទដ្ឋានបច្ចេកទេសដែលបានកំណត់។

ដើម្បីសម្រេចចក្ខុវិស័យដែលបានកំណត់, ក្របខ័ណ្ឌនិម្មាបនកម្មខាងលើនេះ បានដាក់ចេញនូវវិធានការគន្លឹះចំនួន ៤ គឺ៖ ១-ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យគោលរបស់គម្រោងវិនិយោគសាធារណៈដែលជាប្រព័ន្ធសមាហរណកម្មទិន្នន័យកណ្តាលសម្រាប់គម្រោងវិនិយោគសាធារណៈ, ២-ការអភិវឌ្ឍ និងពង្រឹងមុខងារប្រព័ន្ធឌីជីថលដែលមាននៅក្នុងដំណាក់កាលការអនុវត្តគម្រោង, ៣-ការអភិវឌ្ឍមុខងារគាំទ្រការអនុវត្តរំហូរនីតិវិធីការងារសម្រាប់គម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ តាមប្រព័ន្ធឌីជីថលទាំងស្រុង, និង ៤-ការអភិវឌ្ឍនិងពង្រឹងសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធនិងប្រព័ន្ធនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថល នៃគម្រោងវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌ ក.ស.ហ.វ. និងនៅក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈផ្សេងទៀត ទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មខាងលើ នឹងត្រូវធ្វើឡើងជា ២ ដំណាក់កាលក្នុងរយៈពេល ៤ ឆ្នាំ ដោយដំណាក់កាលទី១ (២០២៥-២០២៦) នឹងផ្តោតលើការកសាងមូលដ្ឋានប្រព័ន្ធស្នូល នៃប្រព័ន្ធអេកូ-ឡូស៊ីឌីជីថល ជាមួយនឹងការចាប់ផ្តើមដាក់អនុវត្តជំហានដំបូងនៅរដ្ឋបាលថ្នាក់ជាតិ និងដំណាក់កាលទី ២ (២០២៧-២០២៨) ផ្តោតលើការអភិវឌ្ឍ និងពង្រឹងមុខងារប្រព័ន្ធស្នូល នៃប្រព័ន្ធអេកូឡូស៊ីឌីជីថល ជាមួយនឹងការដាក់បញ្ចូលនូវមុខងារសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការបង្កើនស្វ័យប្រវត្តិកម្មនៃរំហូរនីតិវិធីការងារក្នុងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។

ការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មនេះ ត្រូវអនុលោមទៅតាមគោលការណ៍ និងអភិក្រមនៃគោលនយោបាយរដ្ឋាភិបាលឌីជីថល, ក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយរក្សានិងពង្រឹងប្រព័ន្ធឌីជីថលដែលកំពុងដំណើរការស្រាប់ និងការអភិវឌ្ឍប្រព័ន្ធឌីជីថលថ្មីដែលមានតួនាទីសម្របសម្រួល និងបំពេញបន្ថែមមុខងារដែលនៅខ្វះចន្លោះ ជាមួយនឹងការពង្រឹងអន្តរប្រតិបត្តិការជាលក្ខណៈប្រព័ន្ធអេកូឡូស៊ីឌីជីថលជានាឱ្យបានការឆ្លើយតបទៅនឹងតម្រូវការនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈជាក្របខ័ណ្ឌរួម។

ជារួម, **ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ** នឹងផ្តល់នូវផែនទីបង្ហាញផ្លូវសម្រាប់ឈានឆ្ពោះទៅកាន់ការកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈនៅកម្ពុជាឱ្យបានរឹងមាំ និងមានប្រសិទ្ធភាពខ្ពស់។ ក្របខ័ណ្ឌនេះ នឹងជំរុញការផ្លាស់ប្តូររបៀបធ្វើការតាមបែបឌីជីថលទាំងស្រុង នៅក្នុងដំណើរការនៃការគ្រប់គ្រងនិងការអនុវត្តគម្រោង ដោយធានាថាទិន្នន័យមានរំហូរប្រកបដោយប្រសិទ្ធភាពរវាងអង្គភាព ឬរវាងស្ថាប័ន, ទិន្នន័យមានសង្គតិភាពនិងអាចប្រើប្រាស់បានរួមគ្នា, ទិន្នន័យអាចធ្វើអន្តរប្រតិបត្តិការពេញលេញរវាងប្រព័ន្ធនិងប្រព័ន្ធនៅក្រោមឆ័ត្រនៃ**ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ** ដែលនឹងចូលរួមចំណែកជួយត្រួសត្រាយផ្លូវសម្រាប់អភិបាលកិច្ចឆ្លាតវៃ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

# ១. សេចក្តីផ្តើម

## ១.១. បរិការណ៍ និងសនិទានកម្ម

ស្ថិតក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យុទ្ធសាស្ត្រស្ដីពី ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងគោលបំណងកំណត់ក្របខ័ណ្ឌទស្សនាទានរួមមួយ សម្រាប់បង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន និងនៅគ្រប់កម្រិតរដ្ឋបាល ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និងចីរភាព សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសមធម៌សង្គម។ វិធានការជាយុទ្ធសាស្ត្រមួយក្នុងចំណោមវិធានការនានា នៃយុទ្ធសាស្ត្រខាងលើ បានតម្រង់ទិសក្នុងការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ។

បច្ចុប្បន្ន, ការគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងគម្រោងវិនិយោគសាធារណៈជាក្របខ័ណ្ឌរួម នៅមានកម្រិត ដោយមានការប្រើប្រាស់ប្រព័ន្ធឌីជីថលមួយចំនួន ប៉ុន្តែមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.) បានច្រើននៅឡើយ ជាពិសេសការផ្សារភ្ជាប់ការគ្រប់គ្រងគម្រោងជាមួយនឹងវដ្តនៃគម្រោងវិនិយោគសាធារណៈ។ ជាក់ស្តែង, អគ្គនាយកដ្ឋានចំនួន ២ ក្នុងចំណោមអគ្គនាយកដ្ឋានគន្លឹះចំនួន ៤ នៅក្នុង ក.ស.ហ.វ. បានប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ជាជំនួយដល់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ហើយប្រព័ន្ធទាំងពីរត្រូវបានប្រើប្រាស់ និងអនុវត្តនៅដាច់ដោយឡែកពីគ្នា និងផ្តោតលើមុខងារផ្ទៃក្នុងរៀងៗខ្លួន ដែលមិនទាន់មានភាពប្រទាក់ក្រឡា ឬ មិនទាន់អាចចែករំលែកព័ត៌មានគ្នា។ ការណ៍នេះ, បានបង្កឱ្យមាននូវបញ្ហាប្រឈមមួយចំនួន ដូចជា អសង្គតិភាពនៃទម្រង់ទិន្នន័យ, ការពិបាកក្នុងការផ្ទៀងផ្ទាត់ភាពត្រួតស៊ីគ្នានៃគម្រោងវិនិយោគ ជាពិសេសថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ, ការយឺតយ៉ាវក្នុងការបូកសរុបទិន្នន័យនៃគម្រោងវិនិយោគសាធារណៈជាក្របខ័ណ្ឌរួម, និងការពិបាកក្នុងការវិភាគលើទិដ្ឋភាពនៃការវិនិយោគសាធារណៈ ជាដើម។

ដើម្បីដោះស្រាយបញ្ហាប្រឈមបច្ចុប្បន្ន និងពង្រឹងប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគសាធារណៈឱ្យបានកាន់តែរឹងមាំ និងកាន់តែមានប្រសិទ្ធភាព, ក.ស.ហ.វ. បានផ្តួចផ្តើមរៀបចំនូវក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ សំដៅតម្រង់ទិស និងជំរុញការកសាង ការកែលម្អ និងការប្រើប្រាស់ប្រព័ន្ធឌីជីថល ឱ្យបានជាអតិបរមា សម្រាប់គាំទ្រដល់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាព ផ្អែកតាមគោលបំណងនៃយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ។

## ១.២. គោលបំណង

ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ រៀបចំឡើង ក្នុងគោលបំណង**តម្រង់ទិសជាយុទ្ធសាស្ត្រ និងផ្តល់នូវប្លង់និម្មាបនកម្ម** សម្រាប់ជាមគ្គុទេសក៍ក្នុងការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីឌីជីថល គាំទ្រដល់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅកម្ពុជា។

ក្របខ័ណ្ឌនេះ នឹងផ្តល់នូវមគ្គុទេសក៍ គោលការណ៍ និងអភិក្រម សម្រាប់ការធ្វើទំនើបកម្មការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមប្រព័ន្ធឌីជីថល និងលើកកម្ពស់សមាហរណកម្មប្រព័ន្ធតាមរយៈការធ្វើសន្ទានកម្ម ឬការធ្វើអន្តរប្រតិបត្តិការរវាងប្រព័ន្ធនិងប្រព័ន្ធ នៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ជាពិសេសប្រព័ន្ធឌីជីថលផ្ទៃក្នុង ក.ស.ហ.វ.។

## ១.៣. វិសាលភាព

ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលនេះ ប្រើប្រាស់សម្រាប់គ្រប់គម្រោងវិនិយោគសាធារណៈនៅកម្ពុជា ដែលគ្របដណ្តប់លើ៖

- កម្រិតរដ្ឋបាលថ្នាក់ជាតិ និងកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ,
- គ្រប់ប្រភពហិរញ្ញប្បទាននៃគម្រោងវិនិយោគសាធារណៈ,
- គ្រប់ដំណាក់កាល នៃវដ្តគម្រោងវិនិយោគសាធារណៈ ដោយផ្តោតសំខាន់លើដំណាក់កាលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់ ក.ស.ហ.វ.,
- គ្រប់ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធនឹងគម្រោងវិនិយោគសាធារណៈ រួមមាន៖ អគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ., ក្រសួងផែនការ, ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈ ដែលជាម្ចាស់គម្រោង និងដៃគូអភិវឌ្ឍន៍ ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត,
- គ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការពាក់-ព័ន្ធនឹងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។

## ១.៤. អត្ថប្រយោជន៍

អត្ថប្រយោជន៍សំខាន់ៗ ដែលរំពឹងថាទទួលបានពីក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនេះ រួមមាន៖

- ផ្តល់នូវប្រព័ន្ធទិន្នន័យកណ្តាលរួមមួយ សម្រាប់គម្រោងវិនិយោគសាធារណៈនៅទូទាំងប្រទេស,
- ផ្តល់មូលដ្ឋានរួមសម្រាប់ការសម្រេចចិត្តផ្អែកលើទិន្នន័យ នាំឱ្យការវិភាជធនធានថវិកាបានកាន់តែល្អប្រសើរ និងចំគោលដៅ,
- ពង្រឹងនិងជំរុញកិច្ចសហប្រតិបត្តិការ និងការចែករំលែកទិន្នន័យតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរវាងក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈ សហគ្រាសសា-ធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្ថិតនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ,
- បង្កើនប្រសិទ្ធភាពការងារ តាមរយៈការកាត់តម្រឹមរំហូរនីតិវិធីនៅក្នុងដំណាក់កាលនីមួយៗនៃវដ្តគម្រោង, កាត់បន្ថយការកត់ត្រាស្ទួនគ្នា, កាត់បន្ថយពេលវេលានៃការប្រមូលទិន្នន័យ។ល។,
- ពង្រឹងតម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមរយៈការប្រើប្រាស់ប្រព័ន្ធឌីជីថលទាំងស្រុង,
- កាត់បន្ថយការស្នើគម្រោងវិនិយោគជាន់គ្នា ដែលមានប្រភពហិរញ្ញប្បទានផ្សេងគ្នា និងនៅក្នុងកម្រិតរដ្ឋបាលខុសគ្នា។

# ២. ស្ថានភាពបច្ចុប្បន្ននៃ ការគ្រប់គ្រងគម្រោងវិនិយោគ សាធារណៈ

## ២.១. ក្របខ័ណ្ឌគោលនយោបាយ និងគតិយុត្ត

ផ្អែកលើយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥, យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល ៥ ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល គឺជាឧបករណ៍គោលនយោបាយដ៏សំខាន់សម្រាប់គាំទ្រដល់ការវិនិយោគសាធារណៈនៅកម្ពុជា។ ជាមួយគ្នានេះ, រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មានការរៀបចំនូវផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ផងដែរ។ សម្រាប់ក្របខ័ណ្ឌគតិយុត្ត, យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ បានរំលេចថា **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ** គឺជាបញ្ញត្តិគោលការណ៍គ្រឹះនៃការគ្រប់គ្រង និងប្រើប្រាស់ថវិកាមូលធន និងឥណទានវិនិយោគពីហិរញ្ញប្បទានក្រៅប្រទេសសម្រាប់ការអនុវត្តគម្រោងវិនិយោគសាធារណៈទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយឯកសារ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតកម្រិតអនុក្រឹត្យ ប្រកាស ឬកម្រិតផ្សេងទៀត ត្រូវបានរៀបចំក្រោមក្របខ័ណ្ឌច្បាប់ខាងលើនេះ។ សូមមើលឧបសម្ព័ន្ធទី១ ស្តីពីបញ្ជីឯកសារក្របខ័ណ្ឌគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្ត។

## ២.២. តួអង្គពាក់ព័ន្ធ

តួអង្គដែលពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងការវិនិយោគសាធារណៈ រួមមាន៖

- *ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាម្ចាស់គម្រោង។*
- *ក.ស.ហ.វ.* បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅកម្ពុជា។ អគ្គនាយកដ្ឋាន/អង្គភាពគន្លឹះនៃ ក.ស.ហ.វ. ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងវិនិយោគសាធារណៈ រួមមាន៖
    - *គណៈកម្មការវិនិយោគសាធារណៈ៖* ជាទ្វារបាល នៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន។
    - *នាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា៖* ទទួលបន្ទុកគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិសម្រាប់រដ្ឋបាលថ្នាក់ជាតិ។
    - *អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល៖* ទទួលបន្ទុកគម្រោងវិនិយោគសាធារណៈមានប្រភពហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍ, ពីការឱ្យខ្ចីផ្ទាល់ និងពីមូលបត្ររដ្ឋ។
    - *អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន៖* ទទួលបន្ទុកគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។
    - *អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ៖* ទទួលបន្ទុកត្រួតពិនិត្យការធ្វើថវិកានីយកម្មនិងគម្រោងវិនិយោគសាធារណៈ ពីប្រភពហិរញ្ញប្បទានដោយថវិកាជាតិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- *អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ៖* ទទួលបន្ទុកគម្រោងវិនិយោគសាធារណៈ មានប្រភពហិរញ្ញប្បទានពីការផ្ទេរឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ និងទទួលបន្ទុកបូកសរុបការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋដែលបានពីគម្រោងវិនិយោគសាធារណៈ។
- *អគ្គនាយកដ្ឋានគោលនយោបាយ៖* ជាលេខាធិការដ្ឋានគណៈកម្មការវិនិយោគសាធារណៈ។
- *អគ្គនាយកដ្ឋានថវិកា៖* ទទួលបន្ទុកគ្រប់គ្រងថវិកាជាតិ។
- *អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍៖* ទទួលបន្ទុកដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច និងសង្គមដោយសារគម្រោងអភិវឌ្ឍន៍នានា។
- *មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖* ជាតំណាង ក.ស.ហ.វ. សម្របសម្រួលគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអភិបាលហិរញ្ញវត្ថុ នៅរាជធានី-ខេត្ត។

- *ក្រសួងផែនការ៖* ទទួលបន្ទុកដឹកនាំ សម្របសម្រួល និងរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ដោយមានការចូលរួមពីគ្រប់ក្រសួង-ស្ថាប័ន។
- *ក្រសួងមហាផ្ទៃ៖* ទទួលបន្ទុកសម្របសម្រួល និងរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ ៣ ឆ្នាំរំកិល ដោយមានការចូលរួមពីគ្រប់ក្រសួង-ស្ថាប័ន។

## ២.៣. វដ្តគម្រោងវិនិយោគសាធារណៈ

បច្ចុប្បន្ន, វដ្តគម្រោងវិនិយោគសាធារណៈត្រូវបានកំណត់ជា ៨ ដំណាក់កាល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (សម្រាប់ហិរញ្ញប្បទានដោយថវិកាជាតិ) ប៉ុន្តែការអនុវត្តមានភាពខុសគ្នាបន្តិចបន្តួចនៅរដ្ឋបាលទាំងពីរថ្នាក់។ ខាងក្រោមនេះជា សេចក្តីសង្ខេបនៃដំណាក់កាលនីមួយៗនៅក្នុងវដ្តនៃគម្រោងវិនិយោគសាធារណៈ៖

<u>វដ្តគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ជាតិ</u>

អង្គពាក់ព័ន្ធនៃវដ្តគម្រោងវិនិយោគសាធារណៈនៅរដ្ឋបាលថ្នាក់ជាតិ រួមមាន ក្រសួងផែនការ, ក្រសួង-ស្ថាប័ន ឬអង្គភាពសាធារណៈជាម្ចាស់គម្រោង និង ក.ស.ហ.វ.។ ដំណាក់កាលទាំង ៨ នៃវដ្តគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ជាតិ មានបង្ហាញដូចរូបខាងក្រោម៖

វដ្តទាំង៨នៃគម្រោងវិនិយោគសាធារណៈ(ថ្នាក់ជាតិ)



*រូបភាព 1. ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ជាតិ*

## វដ្តគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

វដ្តគម្រោងវិនិយោគសាធារណៈ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ជា ៨ ដំណាក់កាល ស្រដៀងគ្នានឹងរដ្ឋបាលថ្នាក់ជាតិដែរ, ដោយមានតួអង្គសំខាន់ៗ ដូចជា ក្រុមប្រឹក្សារាជធានី-ខេត្ត, រដ្ឋបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ, ក្រុមប្រឹក្សាឃុំ សង្កាត់, រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ និងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុថ្នាក់មូលដ្ឋាននៃ ក.ស.ហ.វ. គឺអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដំណាក់កាលទាំង ៨ នៃវដ្តគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ មានបង្ហាញដូចរូបខាងក្រោម៖

វដ្តទាំង៨នៃគម្រោងវិនិយោគសាធារណៈ(ថ្នាក់ក្រោមជាតិ)




*រូបភាព 2. ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ*
*(ដកស្រង់ពីគោលការណ៍ណែនាំស្តីពី នីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)*

## ២.៤. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធនឹងគម្រោងវិនិយោគសាធារណៈ

បច្ចុប្បន្ន, អគ្គនាយកដ្ឋានពាក់ព័ន្ធសំខាន់ៗនៃ ក.ស.ហ.វ. ចំនួន ២ បានអភិវឌ្ឍ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគាំទ្រដល់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ គឺអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុលមានប្រព័ន្ធ PPDMS និងនាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកាមានប្រព័ន្ធ DI-PIMS។ ប្រព័ន្ធទាំងពីរនេះ ត្រូវបានប្រើប្រាស់សម្រាប់ការកត់ត្រាព័ត៌មានចាប់ពីដំណាក់កាលអនុវត្តគម្រោងនៃវដ្តគម្រោងវិនិយោគសាធារណៈតែប៉ុណ្ណោះ។ ក្រៅពីនេះ, នៅមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានការពាក់ព័ន្ធមួយចំនួនទៀត រួមមាន៖ ប្រព័ន្ធនៅក្នុង ក.ស.ហ.វ. មានដូចជា FMIS, BPS, DMFAS, PIP-DBMS, SARMIS ជាដើម ដែលភាគច្រើនពាក់ព័ន្ធនៅដំណាក់កាលចាប់ពីការធ្វើថវិកានីយកម្មតទៅ និងប្រព័ន្ធក្រៅសមត្ថកិច្ច ក.ស.ហ.វ. មានដូចជាប្រព័ន្ធគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិលរបស់ក្រសួងផែនការ ដែលអនុវត្តក្នុងដំណាក់កាលទី១ នៃវដ្តគម្រោងវិនិយោគសាធារណៈ។

សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅមិនទាន់មានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគាំទ្រដល់ដំណើរការនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅឡើយទេ ដោយមានតែប្រព័ន្ធមូលដ្ឋានទិន្នន័យមួយចំនួនតូចដែលប្រើប្រាស់សម្រាប់គោលបំណងនៃការកត់ត្រាតិចតួចប៉ុណ្ណោះ ដូចជា ប្រព័ន្ធ sPD និងប្រព័ន្ធ pID

ជាដើម។ ទោះជាយ៉ាងណា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលកំពុងតែដំណើរការបច្ចុប្បន្ន គឺនៅដាច់ដោយឡែកពីគ្នា និងមិនទាន់បានធ្វើសន្ទានកម្ម ចែករំលែកទិន្នន័យស្វ័យប្រវត្តិរវាងគ្នា ដែលអាចជាប្រយោជន៍ក្នុងការធ្វើអន្តរប្រតិបត្តិការនៅឡើយ។

## ប្រព័ន្ធរបស់អគ្គនាយកដ្ឋានពាក់ព័ន្ធសំខាន់ៗនៃ ក.ស.ហ.វ.

***ប្រព័ន្ធ*** *PPDMS (Project Portfolio Database Management System)៖* រៀបចំ និងគ្រប់គ្រងដោយ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល (អ.ស.ប.) សម្រាប់ប្រើប្រាស់ផ្ទៃក្នុង អ.ស.ប. ប៉ុណ្ណោះ ដើម្បីកត់ត្រាព័ត៌មានរបស់គម្រោងចាប់ពីដំណាក់កាលអនុវត្ត ដល់ដំណាក់កាលបញ្ចប់គម្រោង។ ប្រព័ន្ធនេះ អាចតាមដាន និងវាយតម្លៃការអនុវត្តគម្រោង/កម្មវិធីក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ ទាំងហិរញ្ញប្បទានឥតសំណង និងឥណទានដែលស្ថិតក្រោមការត្រួត-ពិនិត្យរបស់ ក.ស.ហ.វ., គម្រោង/កម្មវិធីក្រោមក្របខ័ណ្ឌការឱ្យខ្ចីផ្ទាល់ពីរដ្ឋ និងគម្រោង/កម្មវិធីក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីមូលបត្ររដ្ឋ។ ប្រព័ន្ធនេះបង្កើតឡើងដោយក្រុមការងារបច្ចេកទេសរបស់ អ.ស.ប. ផ្ទាល់ និងដាក់ដំណើរការនៅក្នុងមជ្ឈមណ្ឌលទិន្នន័យរបស់ អ.ស.ប។

***ប្រព័ន្ធ*** *DI-PIMS (Domestic Investment Project Implementation Management System)៖* រៀបចំ និងគ្រប់គ្រងដោយនាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា សម្រាប់ប្រើប្រាស់ផ្ទៃក្នុងនាយកដ្ឋានវិនិយោគប៉ុណ្ណោះ ដើម្បីកត់ត្រា និងតាមដានការអនុវត្តថវិកានៃគម្រោងវិនិយោគសាធារណៈដែលមានប្រភពហិរញ្ញប្បទានពីថវិកាជាតិ និងផ្តោតតែលើដំណាក់កាលនៃការអនុវត្តគម្រោងប៉ុណ្ណោះ។ ប្រព័ន្ធនេះមានមុខងារសំខាន់ៗដូចជា៖ ការកត់ត្រាផែនការថវិកា ការធានាចំណាយ ការតាមដានកិច្ច-លទ្ធកម្ម ការបើកផ្តល់បុរេប្រទាន ការតាមដានការអនុវត្តកិច្ចសន្យា ការទូទាត់គម្រោង និងការរៀបចំរបាយការណ៍។ ប្រព័ន្ធនេះត្រូវបានអភិវឌ្ឍដោយក្រុមហ៊ុនក្នុងស្រុក និងត្រូវបានដាក់ដំណើរការនៅលើក្លោដ (Cloud) ដោយអ្នកផ្គត់ផ្គង់ក្នុងស្រុក។

***ប្រព័ន្ធ*** *PIP-DBMS (Public Investment Project Database Management System)៖* រៀបចំ និងគ្រប់គ្រងដោយអគ្គនាយកដ្ឋានគោលនយោបាយ (អ.គ.ប.) សម្រាប់ប្រមូល និងចងក្រងទិន្នន័យគម្រោងវិនិយោគសាធារណៈក្នុងដំណាក់កាលមុនអនុវត្ត ដំណាក់កាលអនុវត្ត និងក្រោយអនុវត្ត ពីគ្រប់ហិរញ្ញប្បទាន និងគ្រប់កម្រិតរដ្ឋបាល។ បច្ចុប្បន្ន ទិន្នន័យសំខាន់ៗមួយចំនួនត្រូវបានប្រមូល និងរក្សាទុកសម្រាប់ការប្រើប្រាស់គាំទ្រដល់ការបំពេញតួនាទីភារកិច្ចគណៈកម្មការវិនិយោគសាធារណៈ។ ទោះបីជាការប្រមូលទិន្នន័យពុំទាន់បានពេញលេញ និងគ្រប់ជ្រុងជ្រោយតាមតម្រូវការក៏ដោយ, តែទិន្នន័យដែលបានរៀបចំ និងរក្សាទុកក្នុងប្រព័ន្ធនេះ បាននិងកំពុងរួមចំណែកជាបណ្តើរៗ ក្នុងការសិក្សាស្រាវជ្រាវមួយចំនួនរបស់លេខាធិការដ្ឋានគណៈកម្មការវិនិយោគសាធារណៈ។

## ប្រព័ន្ធពាក់ព័ន្ធផ្សេងទៀតនៃ ក.ស.ហ.វ.

***ប្រព័ន្ធ*** *DMFAS (Debt Management and Financial Analysis System)៖* ត្រូវបានអភិវឌ្ឍឡើងដោយសន្និសីទអង្គការសហប្រជាជាតិ ស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) ព្រមទាំងគ្រប់គ្រង និងប្រើប្រាស់ដោយ អ.ស.ប. ក្នុងគោលបំណងគាំទ្រដល់ការគ្រប់គ្រងបំណុលសាធារណៈឱ្យមានប្រសិទ្ធភាព។ ប្រព័ន្ធនេះមានមុខងារកត់ត្រា តាមដាន និងវិភាគទិន្នន័យបំណុលទាំងអស់ រួមមាន ឥណទាន

សម្បទាន ហិរញ្ញប្បទានឥតសំណង និងមូលបត្ររដ្ឋ ជាដើម។ លើសពីនេះទៀត DMFAS មានមុខងារសំខាន់ៗជំនួយដល់ការធ្វើរបាយការណ៍ ព្យាករណ៍ និងវិភាគហានិភ័យបំណុល ដើម្បីផ្តល់ការគាំទ្រដល់ការសម្រេចចិត្ត និងការវាយតម្លៃស្ថានភាព និងស្ថិរភាពបំណុល និងជាយុទ្ធសាស្រ្តចរចាជាមួយដៃគូដែលផ្តល់ឥណទាន។ បច្ចុប្បន្ន ប្រព័ន្ធ DMFAS ត្រូវបានដំឡើងនៅក្នុងម៉ាស៊ីនមេរបស់ អ.ស.ប. ហើយអង្គភាពដែលប្រើប្រាស់មានតែ អ.ស.ប., អ.រ.ត.ន., និង អ.គ.ប. ប៉ុណ្ណោះ។

***ប្រព័ន្ធ*** *FMIS (Financial Management Information System)*៖ រៀបចំ និងគ្រប់គ្រងដោយអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.ប.គ.ហ.) សម្រាប់គាំទ្រដល់ការគ្រប់គ្រងការអនុវត្តថវិកា កិច្ចបញ្ជិកាគណនេយ្យ និងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ។ ប្រព័ន្ធនេះអាចនឹងមានទំនាក់ទំនង ជាមួយប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅក្នុងដំណាក់កាលការអនុវត្តគម្រោង ផ្សារភ្ជាប់នឹងការអនុវត្តថវិកាគម្រោង រួមមាន ការធ្វើចលនាឥណទានថវិកា, ការធានាចំណាយថវិកា, ការអនុវត្តលទ្ធកម្ម, ការទូទាត់ចំណាយ ជាដើម។ ប្រព័ន្ធ FMIS គឺជាប្រព័ន្ធប្រភេទ COTS ដែលកំពុងដំណើរការនៅលើមជ្ឈមណ្ឌលទិន្នន័យដែលគ្រប់គ្រងដោយ អ.ប.គ.ហ. ដែលត្រូវបានដាក់ឱ្យប្រើប្រាស់នៅតាមអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ ក.ស.ហ.វ., អង្គភាពថវិកានៅតាមក្រសួង-ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

***ប្រព័ន្ធ*** *BPS (Budget Planning System)*៖ រៀបចំ និងគ្រប់គ្រងដោយ អ.ប.គ.ហ. គាំទ្រដល់ការងាររៀបចំផែនការថវិកា និងការធ្វើថវិកានីយកម្ម។ ប្រព័ន្ធនេះអាចនឹងមានការពាក់ព័ន្ធជាមួយប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ នៅដំណាក់កាលនៃការធ្វើថវិកានីយកម្មសម្រាប់គម្រោងវិនិយោគសាធារណៈ។ ប្រព័ន្ធ BPS គឺជាប្រព័ន្ធប្រភេទ COTS ដែលកំពុងតែដំណើរការនៅក្នុងមជ្ឈមណ្ឌលទិន្នន័យដែលគ្រប់គ្រងដោយ អ.ប.គ.ហ. និងប្រើប្រាស់ដោយអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ ក.ស.ហ.វ. ជាពិសេសអគ្គនាយកដ្ឋានថវិកា រួមទាំង អង្គភាពថវិកា និងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់។

***ប្រព័ន្ធ*** *SARMIS (State Asset Registry Management Information System)*៖ រៀបចំ និងគ្រប់គ្រងដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច.) ដែលត្រូវបានប្រើប្រាស់សម្រាប់ការចុះបញ្ជី និងកត់ត្រាព័ត៌មានទ្រព្យសម្បត្តិរបស់រដ្ឋរួមមាន ដី អគារ និងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋផ្សេងទៀត។ល។ ប្រព័ន្ធនេះ អាចនឹងមានទំនាក់ទំនងជាមួយប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគ សាធារណៈ នៅដំណាក់កាលនៃការបញ្ចប់គម្រោង និងប្រគល់ទទួលទ្រព្យសម្បត្តិរបស់រដ្ឋដែលជាហេដ្ឋា-រចនាសម្ព័ន្ធរូបវ័ន្ត និងជាសមិទ្ធផលពីការអនុវត្តគម្រោងវិនិយោគសាធារណៈ។

### ប្រព័ន្ធពាក់ព័ន្ធនៅក្រៅ ក.ស.ហ.វ.

ក្រៅពីប្រព័ន្ធដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ ក.ស.ហ.វ., ប្រព័ន្ធពាក់ព័ន្ធមួយចំនួនទៀតដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ដូចជា ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលរបស់ក្រសួងផែនការ, ប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ប្រព័ន្ធគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធនៅតាមក្រសួង-ស្ថាប័ន, ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (Sub-National Project Database និង SNA Project Implementation Database) ជាដើម។




*រូបភាព 3. ការផ្សារភ្ជាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទៅនឹងវដ្តគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ*

## ២.៥. បញ្ហាប្រឈមនៃប្រព័ន្ធគ្រប់គ្រងទិន្នន័យ

ថ្វីត្បិតតែបច្ចុប្បន្ន មានការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ប៉ុន្តែបញ្ហាប្រឈមនៅតែមាន ដូចខាងក្រោម៖

- កង្វះប្រព័ន្ធនៅការដ្ឋានសំខាន់ៗ៖ អគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ. មួយចំនួននៅមិនទាន់មានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដែលខ្លួនទទួលបន្ទុកនៅឡើយ ក្នុងនោះមានគម្រោងដែលមានប្រភពហិរញ្ញប្បទានតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន និងគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកត់ត្រា និងតាមដានការអនុវត្តគម្រោងទាំងពីរនេះ គឺប្រើប្រាស់កម្មវិធី Microsoft Excel ជាគោល។ សម្រាប់អង្គភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺមិនមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាក់លាក់ ក្នុងការគ្រប់គ្រងនិងតាមដានការអនុវត្តគម្រោងនៅឡើយ ដោយមានត្រឹមតែប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការកត់ត្រាទិន្នន័យរក្សាទុកមួយចំនួន និងតាមការស្ម័គ្រចិត្តប៉ុណ្ណោះ។
- កង្វះមុខងារក្នុងប្រព័ន្ធបច្ចុប្បន្ន៖ ប្រព័ន្ធបច្ចុប្បន្នរបស់អគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ. មានមុខងារផ្តោតសំខាន់ចាប់ពីដំណាក់កាលអនុវត្តគម្រោង ដោយមិនទាន់មានមុខងារគាំទ្រដំណាក់កាលមុនការអនុវត្តគម្រោងនៅឡើយ។ ម្យ៉ាងទៀត, ប្រព័ន្ធបច្ចុប្បន្នផ្តោតជាសំខាន់លើការកត់ត្រាទិន្នន័យ ដោយមិនទាន់គិតគូរពីការផ្សារភ្ជាប់ការតាមដានរំហូរការងារនៅឡើយ។
- កង្វះប្រព័ន្ធសមាហរណកម្មទិន្នន័យកណ្តាល៖ ប្រព័ន្ធរបស់អគ្គនាយកដ្ឋានពាក់ព័ន្ធនៃ ក.ស.ហ.វ. ដែលមានស្រាប់ចំនួន ២ នៅដាច់ពីគ្នា ដោយខ្វះប្រព័ន្ធកណ្តាលសម្រាប់ភ្ជាប់សមាហរណកម្មទិន្នន័យរវាងប្រព័ន្ធទាំងពីរ។ ដូចគ្នាដែរ, ប្រព័ន្ធពាក់ព័ន្ធដែលមានស្រាប់ផ្សេងទៀត ដូចជាប្រព័ន្ធ FMIS, BPS, DMFAS ក៏នៅដាច់ដោយឡែកពីប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគសាធារណៈដែលមានស្រាប់, បើទោះបីមានទិន្នន័យមានការផ្សារភ្ជាប់គ្នានឹងគម្រោងវិនិយោគសាធារណៈក៏ដោយ។

- ប្រព័ន្ធរបស់ក្រសួងផែនការ មិនអាចកែសម្រួលបាន៖ ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ជាប្រព័ន្ធចម្បងមួយក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ ដែលមានផ្ទុកព័ត៌មានពាក់ព័ន្ធនឹងកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល សម្រាប់ផ្តល់ជាមូលដ្ឋានទិន្នន័យដើម្បីផ្ទៀងផ្ទាត់ក្នុងដំណាក់កាលស្នើថវិកាគម្រោងទៅ ក.ស.ហ.វ. ប៉ុន្តែបច្ចុប្បន្ន ប្រព័ន្ធនេះមិនអាចកែសម្រួលសម្រាប់ជាកម្មវត្ថុក្នុងការចែករំលែកទិន្នន័យតាមការធ្វើសន្ទានកម្មបានឡើយ។
- ប្រព័ន្ធរបាយការណ៍កណ្តាលនៅមានកម្រិត៖ ប្រព័ន្ធរបាយការណ៍មិនទាន់ធ្វើសន្ទានកម្មជាមួយប្រព័ន្ធដែលមានការពាក់ព័ន្ធនៅក្នុង ក.ស.ហ.វ. បាននៅឡើយ, ទន្ទឹមនេះ ការប្រមូលទិន្នន័យបច្ចុប្បន្នត្រូវពឹងផ្អែកលើការប្រមូលទិន្នន័យដោយដៃ (Manual) ឬមិនស្វ័យប្រវត្តិកម្ម (Non-Automatic) ទាំងស្រុង ដែលជាបញ្ហាប្រឈមពាក់ព័ន្ធនឹងការចំណាយពេលវេលាយូរ ឬមិនទាន់ពេលវេលាក្នុងការផលិតរបាយការណ៍រួម។

# ៣. ក្របខ័ណ្ឌនិម្មាបនកម្ម ប្រព័ន្ធអេកូឡូស៊ីឌីជីថល

ផ្អែកលើស្ថានភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និងបញ្ហាប្រឈមនាពេលកន្លងមក, **ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ** ត្រូវបានផ្តួចផ្តើមរៀបចំឡើងស្របតាមទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម" និងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ។ ក្របខ័ណ្ឌនិម្មាបនកម្មនេះ រៀបចំឡើងផ្អែកតាមមូលដ្ឋាននៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៤ (២០២៣-២០២៧) ដោយអនុលោមតាមគោលការណ៍ នៃក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥។ ក្របខ័ណ្ឌនិម្មាបនកម្មនេះត្រូវបានរៀបចំឡើងតាមម៉ូដែលកូនកាត់ ពោលគឺធានាបាននូវការរក្សានូវការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលកំពុងដំណើរការស្រាប់ និងជំរុញការកសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីដែលទៅបំពេញបន្ថែមចំណុចខ្វះខាតបច្ចុប្បន្ន និងពង្រឹងការធ្វើអន្តរប្រតិបត្តិការជាលក្ខណៈប្រព័ន្ធអេកូឡូស៊ីឌីជីថល។

## ៣.១. ចក្ខុវិស័យ និងវិធានការគន្លឹះ

*ចក្ខុវិស័យ*

ក្របខ័ណ្ឌនិម្មាបនកម្មនេះ រៀបចំឡើងជាមួយនឹងការកំណត់ចក្ខុវិស័យកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈឆ្ពោះទៅរកការគ្រប់គ្រង និងការអនុវត្តគម្រោងវិនិយោគសាធារណៈតាមប្រព័ន្ធឌីជីថលទាំងស្រុង ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការប្រើប្រាស់ថវិកាវិនិយោគឱ្យចំគោលដៅ។ ប្រព័ន្ធអេកូឡូស៊ីឌីជីថល នឹងដើរតួនាទីជាឆ្អឹងខ្នងក្នុងការសម្របសម្រួលភាពប្រទាក់ក្រឡាវាងក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការតម្រឹមវិធាននីតិវិធីអនុវត្តការងារ និងការផ្តល់ព័ត៌មានទាន់ពេលសម្រាប់ការសម្រេចចិត្តលើការវិនិយោគសាធារណៈ ដែលនឹងចូលរួមធ្វើឱ្យប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកាន់តែរឹងមាំ។

*វិធានការគន្លឹះ*

ដើម្បីឈានទៅកាន់ចក្ខុវិស័យខាងលើ, វិធានការគន្លឹះចំនួន ៤ ត្រូវបានដាក់ចេញគឺ៖

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យគោលរបស់គម្រោងវិនិយោគសាធារណៈ ដែលជាប្រព័ន្ធសមាហរណកម្មទិន្នន័យកណ្តាលសម្រាប់គម្រោងវិនិយោគសាធារណៈ (Integrated Public Investment Project Management System – i-PIM)។
- អភិវឌ្ឍ និងពង្រឹងមុខងារប្រព័ន្ធឌីជីថលដែលមាននៅក្នុងដំណាក់កាលការអនុវត្តគម្រោង
- អភិវឌ្ឍមុខងារគាំទ្រការអនុវត្តវិធាននីតិវិធីការងារសម្រាប់គម្រោងវិនិយោគសាធារណៈថ្នាក់ជាតិតាមប្រព័ន្ធឌីជីថលទាំងស្រុង។
- អភិវឌ្ឍនិងពង្រឹងសន្ទានកម្មរវាងប្រព័ន្ធនិងប្រព័ន្ធសម្រាប់ចែករំលែកទិន្នន័យក្នុងប្រព័ន្ធអេកូឡូស៊ី

ឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈទាំងក្នុងក្របខ័ណ្ឌ ក.ស.ហ.វ. និង ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣.២. គោលការណ៍ និងអភិក្រម

*គោលការណ៍*

ក្របខ័ណ្ឌនិម្មាបនកម្មនេះ គោរពទៅតាមគោលការណ៍ដែលមានកំណត់នៅក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥ គឺ៖ **គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក, គោលការណ៍អន្តរ-ប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ និងគោលការណ៍ផ្តួចផ្តើម និងពង្រីកដើម្បីប្រសិទ្ធភាព**។ម្យ៉ាងទៀត ក្របខ័ណ្ឌនិម្មាបនកម្មនេះ ក៏ត្រូវគោរពតាមគោលការណ៍ដែលមានចែងបន្ថែមក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺ៖ **គោលការណ៍ភាពជាម្ចាស់, គោលការណ៍ស្តង់ដារបច្ចេកទេសអភិវឌ្ឍប្រព័ន្ធ, គោលការណ៍ទិន្នន័យបើកចំហ, គោលការណ៍បច្ចេកវិទ្យានិងធនធានរួម និង គោលការណ៍គុណភាពនិងប្រសិទ្ធភាព**។

បន្ថែមពីនេះ, ក្របខ័ណ្ឌនិម្មាបនកម្មនេះ ក៏មានគោលការណ៍ដោយឡែកបន្ថែមផងដែរគឺ៖

- គោលការណ៍រក្សាប្រព័ន្ធចាស់៖ ជំនួសឱ្យការកសាងប្រព័ន្ធថ្មីទាំងស្រុង, ក្របខ័ណ្ឌនិម្មាបនកម្មនេះ តម្រង់ទិសក្នុងការលើកកម្ពស់ និងកែលម្អប្រព័ន្ធដែលមានស្រាប់នៅតាមអង្គភាពជំនាញ ដោយអភិវឌ្ឍប្រព័ន្ធថ្មីសម្រាប់តែអង្គភាពជំនាញដែលមិនទាន់មានប្រព័ន្ធ និងអភិវឌ្ឍប្រព័ន្ធកណ្តាលរួមមួយដើម្បីបំពេញបន្ថែមមុខងារដែលខ្វះចន្លោះ។
- គោលការណ៍វដ្តនៃគម្រោងវិនិយោគសាធារណៈ៖ ការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថល គឺត្រូវផ្តោតទៅលើដំណាក់កាលនីមួយៗនៃវដ្តគម្រោងវិនិយោគសាធារណៈ។
- គោលការណ៍សាមញ្ញភាព៖ ការកសាងប្រព័ន្ធត្រូវធ្វើយ៉ាងណាឱ្យងាយស្រួលប្រើប្រាស់ និងឆ្លើយតបតាមតម្រូវការការងាររបស់ការដ្ឋានប្រើប្រាស់ប្រព័ន្ធ។

*អភិក្រម*

ដើម្បីជំរុញក្របខ័ណ្ឌនិម្មាបនកម្មនេះ ឱ្យប្រព្រឹត្តទៅបានរលូន និងមានប្រសិទ្ធភាព គឺត្រូវអនុលោមទៅតាមអភិក្រម នៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺ៖ ១-មនុស្ស (People)៖ ការលើកកម្ពស់ និងការប្រើប្រាស់មូលធនមនុស្សឱ្យអស់សក្តានុពល, ២-នីតិវិធីប្រតិបត្តិការ (Process)៖ តម្រឹមរំហូរនីតិវិធីអនុវត្តការងារឱ្យបានតាមប្រព័ន្ធឌីជីថលទាំងស្រុង និង ៣-បច្ចេកវិទ្យា (Technology)៖ ការប្រើប្រាស់ឱ្យអស់សក្តានុពលធនធានបច្ចេកវិទ្យាព័ត៌មានរួម។

ជាមួយគ្នានេះ, ក្របខ័ណ្ឌនិម្មាបនកម្មនេះ បានកំណត់អភិក្រមផ្ទាល់ចំនួន ៤ គឺ៖ ១-ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃ ក.ស.ហ.វ., ២-កំហិតចំនួនប្រព័ន្ធនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, ៣-ដាក់ចំណោលអនុវត្តរំហូរការងារតាមដំណាក់កាលនីមួយៗនៃវដ្តគម្រោងវិនិយោគសាធារណៈតាមប្រព័ន្ធអនឡាញទាំងស្រុង និង ៤-កំណត់មុខងារគ្រប់គ្រងព័ត៌មានគោលរបស់គម្រោងវិនិយោគសាធារណៈ ទាំងរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។




*រូបភាព 4. អភិក្រមនៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ*

## ៣.៣. និម្មាបកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថល

និម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ត្រូវបានកំណត់ជាបីផ្នែកធំគឺ ១-ផ្នែកមុខងារប្រព័ន្ធ, ២- ផ្នែកប្រព័ន្ធអេកូឡូស៊ីឌីជីថល, និង ៣-ផ្នែកក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ.។ ផ្នែកទាំងបីនេះ ក៏អនុលោមទៅតាមស្រទាប់ទាំង ៤ នៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ. ផងដែរគឺ ស្រទាប់ធុរកិច្ច, ស្រទាប់ទិន្នន័យ, ស្រទាប់កម្មវិធី និងស្រទាប់បច្ចេកវិទ្យា។

១-**មុខងារប្រព័ន្ធ៖** ផ្នែកនេះផ្សារភ្ជាប់នឹងស្រទាប់ធុរកិច្ចនៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ. គឺសំដៅទៅលើសំណុំនៃមុខងារប្រព័ន្ធ សម្រាប់គាំទ្រប្រតិបត្តិការធុរកិច្ចក្នុងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដោយចែកចេញជា**មុខងារស្នូល និងមុខងារគាំទ្រ**។ មុខងារស្នូលរបស់ប្រព័ន្ធ សំដៅដល់មុខងារទិន្នន័យគោលនៃគម្រោងវិនិយោគសាធារណៈ និងមុខងារដែលអនុវត្តនៅដំណាក់កាលនីមួយៗនៃវដ្តគម្រោងវិនិយោគសាធារណៈ ដូចជា មុខងារស្នើនិងវាយតម្លៃគម្រោង, មុខងារថវិកាគម្រោង, មុខងារអនុវត្តគម្រោង, មុខងារកែសម្រួលគម្រោង និងមុខងារបិទបញ្ចប់គម្រោង។ សម្រាប់មុខងារគាំទ្ររបស់ប្រព័ន្ធ មានដូចជា មុខងារគ្រប់គ្រងលំហូរការងារនិងការអនុម័ត, មុខងារគ្រប់គ្រងសិទ្ធិប្រើប្រាស់, មុខងារផ្តល់ព័ត៌មាន, មុខងារទំនាក់ទំនងឆ្លើយឆ្លងគ្នា, មុខងាររបាយការណ៍និងវិភាគ, មុខងារកំណត់ត្រាសកម្មភាពនិងសវនកម្ម, ជាដើម។

២-**ប្រព័ន្ធអេកូឡូស៊ីឌីជីថល៖** ផ្នែកនេះផ្សារភ្ជាប់ទៅស្រទាប់កម្មវិធី និងស្រទាប់ទិន្នន័យនៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ.។ *ស្រទាប់កម្មវិធី* គឺជាសំណុំនៃប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានស្ថិតក្នុងប្រព័ន្ធអេកូឡូស៊ី នៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដែលចែកជា ៣ សំណុំនៃប្រព័ន្ធឌីជីថល គឺ ១-សំណុំនៃប្រព័ន្ធស្នូលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, ២-សំណុំនៃប្រព័ន្ធដែលពាក់ព័ន្ធនៅក្នុង ក.ស.ហ.វ. និង ៣-សំណុំនៃប្រព័ន្ធដែលពាក់ព័ន្ធនៅក្រៅ ក.ស.ហ.វ.។ ប្រព័ន្ធដែលស្ថិតនៅក្នុងសំណុំនៃប្រព័ន្ធនីមួយៗ នឹងត្រូវធ្វើសន្ទានកម្មជាមួយប្រព័ន្ធស្នូលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈផ្អែកតាមកម្រិតនៃភាពប្រទាក់ក្រឡាគ្នា។ សម្រាប់ *ស្រទាប់ទិន្នន័យ* គឺសំដៅទៅលើការគ្រប់គ្រងបណ្តុំទិន្នន័យរក្សាទុកនៅតាមប្រព័ន្ធនីមួយៗ ឆ្លើយតបទៅនឹងតម្រូវការនៃមុខងារក្នុងធុរកិច្ច, ការកំណត់នូវយន្តការចែករំលែកទិន្នន័យ, ក្របខ័ណ្ឌអន្តរប្រតិបត្តិការ និងក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ នៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃគម្រោងវិនិយោគសាធារណៈ។

៣-**ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ.៖** ផ្នែកនេះផ្សារភ្ជាប់ជាសំខាន់ទៅលើស្រទាប់បច្ចេកវិទ្យា នៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ. ដែលសំដៅដល់ហេដ្ឋារចនាសម្ព័ន្ធនិងថ្នាលបច្ចេកវិទ្យាព័ត៌មានគ្រឹះ ដូចជា មជ្ឈមណ្ឌលទិន្នន័យ, ម៉ាស៊ីនមេ, បណ្ដាញគមនាគមន៍, ថ្នាលឌីជីថលគ្រឹះ (CamDigiKey, CamDX), មជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខសាយប័រ, កម្មវិធីសម្រាប់អភិវឌ្ឍប្រព័ន្ធ ដូចជា NestJS, NextJS, PosgreSQL, Kubernet, Redis ជាដើម។




*រូបភាព 5. ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ*

## ៣.៤. ប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃគម្រោងវិនិយោគសាធារណៈ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ត្រូវបានកំណត់ជាបណ្តុំនៃប្រព័ន្ធច្រើនដែលធ្វើអន្តរប្រតិបត្តិការរួមគ្នាជាប្រព័ន្ធអេកូឡូស៊ីឌីជីថលតែមួយ។ ក្នុងន័យនេះ, អគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ. ដែលមានប្រព័ន្ធផ្ទាល់ខ្លួន, អាចបន្តការអភិវឌ្ឍ និងកែលម្អប្រព័ន្ធរបស់ខ្លួនបន្ថែម ដើម្បីអាចធ្វើប្រតិបត្តិការនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលបាន។ ដោយឡែក អគ្គនាយកដ្ឋាននៃ ក.ស.ហ.វ. ដែលមិនទាន់មានប្រព័ន្ធប្រើប្រាស់, អាចធ្វើការកសាងប្រព័ន្ធថ្មីសម្រាប់គ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈជាលក្ខណៈលម្អិតផ្ទៃក្នុង ដែលស្ថិតក្នុងភារកិច្ចរបស់ខ្លួន។ ដូចគ្នានេះដែរ, ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្ថិតនៅក្នុងប្រព័ន្ធអេកូឡូស៊ីសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និងមានប្រព័ន្ធប្រើប្រាស់រួចហើយ ក៏នៅតែបន្តប្រើប្រាស់ប្រព័ន្ធរបស់ខ្លួនដដែល ដោយប្រព័ន្ធទាំងនោះអាចនឹងត្រូវការ ការកែលម្អបន្ថែមមួយចំនួនដើម្បីអាចភ្ជាប់ទៅកាន់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CAMDX) ឬការបន្ថែមនូវតម្រូវការទិន្នន័យនិងមុខងារមួយចំនួនទៀត។

ទោះបីជាអគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ. មានប្រព័ន្ធប្រើប្រាស់រៀងៗខ្លួនសម្រាប់គ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈទៅតាមប្រភពហិរញ្ញប្បទាន, ក៏នៅតែចាំបាច់ត្រូវការកសាងប្រព័ន្ធសមាហរណកម្មទិន្នន័យកណ្តាលមួយ (Integrated Public Investment Project Management Information System – i-PIM) សម្រាប់ធ្វើសមាហរណកម្ម ធ្វើអន្តរប្រតិបត្តិការ កំណត់ស្តង់ដារ និងបង្កើតរបាយការណ៍វិភាគជាក្របខ័ណ្ឌនៃការវិនិយោគសាធារណៈរួមនៅទូទាំងប្រទេស។




*រូបភាព 6. ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ*

ជារួម, ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ផ្សំឡើងដោយសំណុំនៃប្រព័ន្ធឌីជីថលជាច្រើន ដូចជា ១-ប្រព័ន្ធស្នូលនៃគម្រោងវិនិយោគសាធារណៈ រួមមាន ប្រព័ន្ធសមាហរណកម្មទិន្នន័យកណ្តាលនៃគម្រោងវិនិយោគសាធារណៈ (i-PIM) និងប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងរបស់អគ្គនាយកដ្ឋានសំខាន់ៗទាំង ៤ នៃ ក.ស.ហ.វ., ២-ប្រព័ន្ធពាក់ព័ន្ធនឹងគម្រោងវិនិយោគសាធារណៈនៅក្នុង ក.ស.ហ.វ. រួមមាន BPS, FMIS, SARMIS, DMFAS និង ៣-ប្រព័ន្ធពាក់ព័ន្ធនឹងគម្រោងវិនិយោគសាធារណៈនៅតាមក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាលសហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាប្រព័ន្ធគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិលរបស់ក្រសួងផែនការ, ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោម-ជាតិ, ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, ប្រព័ន្ធគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាដើម។

*ប្រព័ន្ធសមាហរណកម្មទិន្នន័យកណ្តាល (i-PIM)*

i-PIM គឺជាប្រព័ន្ធដែលនឹងត្រូវបង្កើត និងសម្របសម្រួលការអភិវឌ្ឍផ្នែកបច្ចេកទេស (Technical Development) ដោយអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ជាមួយនឹងការសម្របសម្រួលផ្នែកនីតិវិធីអនុវត្តនិងកិច្ចដំណើរការ (Business Process) ដោយអគ្គនាយកដ្ឋានគោលនយោបាយ ដែលជាលេខាធិការដ្ឋានគណៈកម្មការវិនិយោគសាធារណៈ នៃ ក.ស.ហ.វ. ក្នុងនាមជាអ្នកគ្រប់គ្រងការអនុវត្តការងារ (Business Owner)។ ប្រព័ន្ធនេះមានតួនាទីជាប្រព័ន្ធកណ្តាល សម្រាប់ភ្ជាប់ទៅកាន់ប្រព័ន្ធឌីជីថលនានារបស់អគ្គ-នាយកដ្ឋានសំខាន់ៗនៅក្នុង ក.ស.ហ.វ. និងប្រព័ន្ធពាក់ព័ន្ធផ្សេងទៀត។ ប្រព័ន្ធនេះបង្កើតឡើងក្នុងតួនាទីជាច្រកចេញ-ចូល ក.ស.ហ.វ. ជាមួយម្ចាស់គម្រោង, ជាអ្នកសម្របសម្រួលលំហូរនីតិវិធីជាមួយអគ្គនាយក-ដ្ឋានគន្លឹះនៅក្នុង ក.ស.ហ.វ., ជាអ្នកធ្វើសមាហរណកម្មនិងធ្វើអន្តរប្រតិបត្តិការទិន្នន័យ, ជាអ្នកបូកសរុបរបាយការណ៍និងជាអ្នកវិភាគក្នុងទិដ្ឋភាពរួមនៃគម្រោងវិនិយោគសាធារណៈនៅទូទាំងប្រទេស។ ប្រព័ន្ធនេះនឹងផ្តល់នូវផតថល (Portal) រួមសម្រាប់តួអង្គពាក់ព័ន្ធ ជាពិសេសម្ចាស់គម្រោង ដើម្បីធ្វើការបង្កើតនិងបញ្ចូលទិន្នន័យគម្រោង, បញ្ជូនឯកសារគម្រោង, ដាក់ស្នើគម្រោងជាមួយ ក.ស.ហ.វ., តាមដានដំណើរ-ការការស្នើសុំ, កត់ត្រាព័ត៌មានស្តីពីការអនុវត្តគម្រោង ជាដើម ដោយប្រព័ន្ធនេះនឹងបញ្ជូនទិន្នន័យទៅកាន់ប្រព័ន្ធឌីជីថលរបស់អគ្គនាយកដ្ឋានទទួលបន្ទុកនៃ ក.ស.ហ.វ.។

ក្នុងករណីម្ចាស់គម្រោងមានប្រព័ន្ធឌីជីថលកំពុងប្រើប្រាស់ សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ គឺអាចធ្វើការសិក្សាពិនិត្យលទ្ធភាពក្នុងការធ្វើសន្ទានកម្មជាមួយប្រព័ន្ធ i-PIM តែម្តង។

*ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគនៃអគ្គនាយកដ្ឋានសំខាន់ៗ នៃ ក.ស.ហ.វ.*

ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈនៅក្នុង ក.ស.ហ.វ. ត្រូវបានកំណត់ថាមានប្រព័ន្ធចំនួន ៤ ផ្អែកតាមគម្រោងវិនិយោគសាធារណៈ ដែលមានហិរញ្ញប្បទានពីប្រភពផ្សេងៗគ្នា និងទទួលបន្ទុកនៅតាមអគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ. ចំនួន ៤។ បច្ចុប្បន្ននេះ **ប្រព័ន្ធចំនួន ២ កំពុងដំណើរការ** គឺប្រព័ន្ធ PPDMS សម្រាប់គម្រោងវិនិយោគសាធារណៈមានប្រភពហិរញ្ញប្បទានក្រៅប្រទេស និងប្រព័ន្ធ DI-PIMS សម្រាប់គម្រោងវិនិយោគសាធារណៈមានប្រភពហិរញ្ញប្បទានពីថវិកាជាតិនៅរដ្ឋបាល

ថ្នាក់ជាតិ ប៉ុន្តែប្រព័ន្ធទាំងពីរនេះអាចនឹងត្រូវកែសម្រួលមុខងារបច្ចេកទេសមួយចំនួន ដើម្បីមានលទ្ធភាពអាចធ្វើសមាហរណកម្មទិន្នន័យក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលថ្មី។ ដោយឡែក ប្រព័ន្ធចំនួន ២ ទៀត គឺចាំបាច់ត្រូវតែបង្កើតថ្មី ស្របតាមលក្ខណៈពិសេសដោយឡែកពីគ្នា គឺប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP-PIMS) និងប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ មានហិរញ្ញប្បទានពីថវិកាជាតិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA-PIMS)។

ប្រព័ន្ធទាំង ៤ នេះនឹងត្រូវសន្ទានកម្មជាមួយប្រព័ន្ធកណ្ដាល i-PIM ដើម្បីផ្លាស់ប្ដូរទិន្នន័យដែលបញ្ជូនពីម្ចាស់គម្រោង, ធ្វើបច្ចុប្បន្នភាពព័ត៌មានទៅ កាន់ម្ចាស់គម្រោងវិញ និងផ្ទៀងផ្ទាត់ព័ត៌មានគម្រោងវិនិយោគសាធារណៈជារួម។ ប្រព័ន្ធទាំង ៤ អាចមុខងារសំខាន់ៗមួយចំនួន ដូចជា ការគ្រប់គ្រងការស្នើនិងការជ្រើសរើសគម្រោង, ការគ្រប់គ្រងការអនុវត្តគម្រោង រួមមាន ការរាយការណ៍ពីវឌ្ឍនភាពគម្រោង ការតាមដានការអនុវត្តកិច្ចសន្យា ការតាមដានការអនុវត្តថវិកា ជាដើម, ការគ្រប់គ្រងរំហូរការងារនិងឯកសារផ្ទៃក្នុង, ការគ្រប់គ្រងការបញ្ចប់គម្រោង ជាដើម។

*ប្រព័ន្ធពាក់ព័ន្ធនៅក្នុង ក.ស.ហ.វ. និងនៅក្រៅសមត្ថកិច្ច ក.ស.ហ.វ.*

នៅក្នុង ក.ស.ហ.វ., ប្រព័ន្ធដែលមានការពាក់ព័ន្ធទៅនឹងគម្រោងវិនិយោគសាធារណៈ មានដូចជា ប្រព័ន្ធ BPS អាចពាក់ព័ន្ធនឹងការធ្វើថវិកានីយកម្ម, ប្រព័ន្ធ FMIS អាចពាក់ព័ន្ធការអនុវត្តថវិកាគម្រោង, ប្រព័ន្ធ SARMIS អាចពាក់ព័ន្ធនឹងការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ និងប្រព័ន្ធ DMFAS អាចពាក់ព័ន្ធនឹងគម្រោងហិរញ្ញប្បទានពីក្រៅប្រទេស ដែលប្រព័ន្ធទាំងនេះនឹងដាក់បញ្ចូលទៅក្នុងទិសដៅការងារសន្ទានកម្មជាមួយនឹងប្រព័ន្ធស្នូលនៃគម្រោងវិនិយោគសាធារណៈ។

ដូចគ្នានេះ, នៅតាមក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈផ្សេងទៀត ក៏អាចនឹងមានប្រព័ន្ធដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគសាធារណៈផងដែរ ដូចជា ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល របស់ក្រសួងផែនការ ជាដើម ដែលត្រូវដាក់បញ្ចូលក្នុងទិសដៅការងារសន្ទានកម្មជាបន្តបន្ទាប់ជាមួយប្រព័ន្ធស្នូលនៃគម្រោងវិនិយោគសាធារណៈ ដើម្បីពង្រីកសមត្ថភាពប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ឱ្យកាន់តែល្អប្រសើរ និងមានស្វ័យប្រវត្តិកម្មខ្ពស់។

## ៣.៥. តួអង្គនិងតួនាទីនៅក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថល

អង្គសំខាន់ៗ នៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ មានដូចតទៅ៖

*អង្គភាពនៃ ក.ស.ហ.វ.*

គណៈកម្មការវិនិយោគសាធារណៈ នៃ ក.ស.ហ.វ.៖ តម្រង់ទិស និងជំរុញការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអេកូឡូស៊ីឌីជីថលដែលជាថ្នាលរួម នៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន និងជាទ្វារបាលនៃការចុះបញ្ជី និងពិនិត្យផ្ទៀងផ្ទាត់គម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន ។

*អគ្គនាយកដ្ឋានគោលនយោបាយ៖* ចូលរួមអភិវឌ្ឍ និងកែលម្អប្រព័ន្ធ i-PIM ក្នុងតួនាទីជាអ្នកគ្រប់គ្រង និងដំណើរការប្រព័ន្ធ, កំណត់ទិសដៅសម្រាប់ការអនុវត្តប្រព័ន្ធ និងកំណត់លក្ខខណ្ឌមុខងារមួយចំនួនរបស់ប្រព័ន្ធ ជាពិសេសមុខងារវិភាគ មុខងាររបាយការណ៍ និងមុខងារវាយតម្លៃការជ្រើសរើសគម្រោង និងកំណត់ស្តង់ដាតម្រូវការទិន្នន័យ និងចុះបញ្ជីគ្រប់គម្រោងវិនិយោគសាធារណៈដែលស្នើមក ក.ស.ហ.វ. និងបូកសរុបវឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគសាធារណៈ។

*អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល៖* ទទួលបន្ទុកផ្នែកបច្ចេកទេសឌីជីថលលើប្រព័ន្ធ i-PIM ដោយត្រូវធ្វើការអភិវឌ្ឍ កែលម្អ និងគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធ ព្រមទាំងធ្វើការសម្របសម្រួលសហការក្នុងការភ្ជាប់សន្ទានកម្មជាមួយប្រព័ន្ធដែលពាក់ព័ន្ធ រួមទាំង ការសម្របសម្រួលក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធ ជាជំហានៗ។

*អគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ.៖* សំដៅទៅលើនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល, អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទីគ្រប់គ្រងការអភិវឌ្ឍ កែលម្អ និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ ត្រឹមកម្រិតផ្ទៃក្នុងរបស់ខ្លួន ដើម្បីទទួល ពិនិត្យ និងបញ្ជាក់ការអនុម័តលើសំណើគម្រោង, តាមដានការអនុវត្តគម្រោង, គ្រប់គ្រងលំហូរការងារ និងឯកសារផ្ទៃក្នុង ជាដើម និងត្រូវសហការជាមួយអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ក្នុងការធ្វើសន្ទានកម្មទិន្នន័យជាមួយនឹងប្រព័ន្ធ i-PIM, ធ្វើអន្តរប្រតិបត្តិការទិន្នន័យ និងផ្លាស់ប្តូរទិន្នន័យចាំបាច់សម្រាប់ជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់ និងការតម្រង់ទិសការវិនិយោគសាធារណៈឱ្យបានល្អប្រសើរ។

*អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ៖* គ្រប់គ្រងនិងធ្វើប្រតិបត្តិការលើប្រព័ន្ធ SARMIS ដែលអាចនឹងត្រូវសហការរៀបចំសន្ទានកម្មទិន្នន័យជាមួយប្រព័ន្ធ i-PIM។

*អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖* ផ្តល់កិច្ចសហការក្នុងការធ្វើសន្ទានកម្មប្រព័ន្ធដែលខ្លួនទទួលបន្ទុក រួមមាន ប្រព័ន្ធ BPS និង ប្រព័ន្ធ FMIS ជាមួយនឹងប្រព័ន្ធ i-PIM ឬប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈរបស់អគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ.។

*ក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ.៖* ផ្តល់ការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដូចជា មជ្ឈមណ្ឌលទិន្នន័យ, មជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខសាយប័រ, គោលការណ៍ឬស្តង់ដារបច្ចេកវិទ្យាព័ត៌មាន ជាដើម។

*មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖* ប្រើប្រាស់ប្រព័ន្ធ i-PIM ក្នុងការតាមដានការអនុវត្តគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកតាមតួនាទីនិងភារកិច្ចដែលមានកំណត់ក្នុងវដ្តគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### *ស្ថាប័នពាក់ព័ន្ធខាងក្រៅ ក.ស.ហ.វ.*

*ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ដែលជាម្ចាស់គម្រោង៖* ប្រើប្រាស់ប្រព័ន្ធ i-PIM សម្រាប់បញ្ជូនការស្នើគម្រោង, តាមដានការស្នើគម្រោង, ធ្វើបច្ចុប្បន្នភាពអំពីគម្រោង ជាដើម ជាមួយ ក.ស.ហ.វ. និងផ្តល់កិច្ចសហការសន្ទានកម្មប្រព័ន្ធរបស់ខ្លួន (ក្នុងករណីមានប្រព័ន្ធពាក់ព័ន្ធ) ជាមួយប្រព័ន្ធ i-PIM។

*រដ្ឋបាលថ្នាក់ក្រោមជាតិដែលជាម្ចាស់គម្រោង៖* ប្រើប្រាស់ប្រព័ន្ធ i-PIM សម្រាប់ទំនាក់ទំនងការងារជាមួយអង្គភាពទទួលបន្ទុកនៃ ក.ស.ហ.វ. ក្នុងក្របខ័ណ្ឌការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

*ក្រសួងផែនការ៖* សម្របសម្រួល និងផ្តល់កិច្ចសហការក្នុងការធ្វើសន្ធានកម្ម រវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ជាមួយប្រព័ន្ធ i-PIM។

*ក្រសួងមហាផ្ទៃ៖* សម្របសម្រួល និងផ្តល់កិច្ចសហការក្នុងការភ្ជាប់សន្ធានកម្ម រវាងប្រព័ន្ធ i-PIM ជាមួយប្រព័ន្ធដែលមានការពាក់ព័ន្ធរបស់ក្រសួងមហាផ្ទៃ សម្រាប់ការគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ៤. ផែនការអនុវត្ត

ដោយពិនិត្យឃើញថា **ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ** មានតួអង្គច្រើនដែលចូលរួមអនុវត្ត និងមានបណ្ដុំនៃប្រព័ន្ធបច្ចេកវិទ្យា-ព័ត៌មានច្រើនដែលមានការពាក់ព័ន្ធគ្នា ទាំងប្រព័ន្ធមានស្រាប់ និងប្រព័ន្ធត្រូវបង្កើតថ្មី, ដូចនេះ ការរៀបចំផែនការអនុវត្ត គឺផ្ដោតជាសំខាន់ទៅលើសកម្មភាពដែលទទួលបន្ទុកដោយតួអង្គជាអង្គភាពនៃ ក.ស.ហ.វ. និងសកម្មភាពដែលពាក់ព័ន្ធនឹងប្រព័ន្ធនៅក្នុង ក.ស.ហ.វ.។ ម្យ៉ាងទៀត, ការអនុវត្តក្របខ័ណ្ឌនេះ គឺត្រូវយកការគិតគូរជាលក្ខណៈពីតូចទៅធំជាជំហាន, ការសម្របសម្រួលនិងការសហការខ្ពស់ និងការសម្របខ្លួនបន្តិចម្ដងៗ នៅក្នុងប្រព័ន្ធអេកូឡូស៊ីសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈបែបទំនើបកម្មថ្មី។

## ៤.១. យុទ្ធសាស្ត្រនៃការអនុវត្ត

យុទ្ធសាស្ត្រសម្រាប់ការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មនេះ គឺផ្ដោតលើការអភិវឌ្ឍ, ការពង្រឹង និងការពង្រីកប្រព័ន្ធឌីជីថល គាំទ្រដល់ដំណើរការនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដោយឈរលើគោលការណ៍ "**ចាប់ផ្ដើមពីតូច និងសាមញ្ញ ប៉ុន្តែរឹងមាំ និងអាចពង្រីកបាន**"។ យុទ្ធសាស្ត្រនៃការអនុវត្តនេះ បានតម្រង់ទិសលើចំណុចគោលចំនួន ២ គឺៈ ១-ការអភិវឌ្ឍប្រព័ន្ធថ្មី និងការកែលម្អប្រព័ន្ធដែលមានស្រាប់ និង ២-ការពង្រីក និងពង្រឹងការអនុវត្តប្រព័ន្ធ និងការធ្វើសន្ទានកម្មរវាងប្រព័ន្ធ។

### សកម្មភាពគន្លឹះនៃយុទ្ធសាស្ត្រ រួមមានៈ

- អភិវឌ្ឍប្រព័ន្ធ i-PIM ថ្មី ដែលចាប់ផ្ដើមពីមុខងារស្នូលនៅដំណាក់កាលមុនការអនុវត្តគម្រោងវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងពង្រីកមុខងារស្នូលជាបន្តបន្ទាប់ មុននឹងអភិវឌ្ឍមុខងារគាំទ្រ និងមុខងារសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីចំនួន ២ គឺ ទី១-ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន និងទី២-ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានថវិកាជាតិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ពង្រឹងមុខងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានស្រាប់ចំនួន ២ ដើម្បីសម្របខ្លួនចូលទៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ រួមមាន ១-ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ មានហិរញ្ញប្បទានពីក្រៅប្រទេស និង ២-ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ មានហិរញ្ញប្បទានដោយថវិកាជាតិសម្រាប់រដ្ឋបាលថ្នាក់ជាតិ។
- ពង្រីកការធ្វើសន្ទានកម្មរវាងប្រព័ន្ធ i-PIM ជាមួយប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងរបស់អគ្គ-នាយកដ្ឋានគន្លឹះនៃ ក.ស.ហ.វ. ទាំង ៤, សន្ទានកម្មជាមួយប្រព័ន្ធពាក់ព័ន្ធនៅក្នុង ក.ស.ហ.វ. និងសន្ទានកម្មជាមួយប្រព័ន្ធពាក់ព័ន្ធខាងក្រៅ ក.ស.ហ.វ.។

- ដាក់ឱ្យអនុវត្តនិងពង្រីកការអនុវត្តប្រព័ន្ធ i-PIM ជាជំហានៗ ផ្ដើមចេញពីអគ្គនាយកដ្ឋានសំខាន់ៗ នៃ ក.ស.ហ.វ., បន្តអនុវត្តនៅក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល នៃរដ្ឋបាលថ្នាក់ជាតិ ដែលជាម្ចាស់គម្រោង និងបន្ទាប់មកអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាម្ចាស់គម្រោង។
- ពង្រីកការអនុវត្តរំហូរនីតិវិធីអនុវត្តការងារតាមប្រព័ន្ធឌីជីថលទាំងស្រុង សម្រាប់ដំណាក់កាលនីមួយៗនៃវដ្តគម្រោងវិនិយោគសាធារណៈ។

## ៤.២. ទិសដៅអនុវត្ត

ការអនុវត្ត **ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគ សាធារណៈ** ធ្វើឡើងជាដំណាក់កាលដោយគិតសម្រាប់រយៈពេល ៤ ឆ្នាំដំបូង ដូចតទៅ៖

***ដំណាក់កាលទី១ (២០២៥-២០២៦)៖*** កសាងមូលដ្ឋានប្រព័ន្ធស្នូល នៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដោយផ្ដោតលើរដ្ឋបាលថ្នាក់ជាតិ និងចាប់ផ្ដើមដាក់ឱ្យអនុវត្តជំហានដំបូងនៅក្រសួងមួយចំនួន។ ដំណាក់កាលនេះ ត្រូវសម្រេចឱ្យបានលទ្ធផល ដូចតទៅ៖

- អភិវឌ្ឍប្រព័ន្ធថ្មីចំនួន ២ នៅក្នុងសំណុំនៃប្រព័ន្ធស្នូល រួមមាន ១-ប្រព័ន្ធ i-PIM ដែលផ្ដោតលើគម្រោងវិនិយោគសាធារណៈរដ្ឋបាលថ្នាក់ជាតិ និង ២-ប្រព័ន្ធ PPP-PIMS សម្រាប់គ្រប់គ្រងការអនុវត្តគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។
- អភិវឌ្ឍសន្ទានកម្មរវាងប្រព័ន្ធ i-PIM និងប្រព័ន្ធ PPP-PIMS និងការសិក្សាលទ្ធភាពសន្ទានកម្មប្រព័ន្ធ i-PIM ជាមួយប្រព័ន្ធរបស់ក្រសួងផែនការ។
- ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ i-PIM នៅតាមអគ្គនាយកដ្ឋានគន្លឹះនៃ ក.ស.ហ.វ. និងម្ចាស់គម្រោងដែលជាក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈមួយចំនួននៅរដ្ឋបាលថ្នាក់ជាតិ។

***ដំណាក់កាលទី២ (២០២៧-២០២៨)៖*** អភិវឌ្ឍនិងពង្រឹងមុខងារប្រព័ន្ធស្នូលនៃប្រព័ន្ធអេកូឡូ-ឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ រួមបញ្ចូលការគិតគូរបញ្ចូលមុខងារសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើនស្វ័យប្រវត្តិកម្មនៃរំហូរនីតិវិធីការងារក្នុងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ ដំណាក់កាលនេះ ត្រូវសម្រេចឱ្យបានលទ្ធផលដូចតទៅ៖

- បន្តអភិវឌ្ឍនិងពង្រឹងមុខងារនៃប្រព័ន្ធនីមួយៗនៅក្នុងសំណុំប្រព័ន្ធស្នូលគឺ ១-បន្តការអភិវឌ្ឍនិងពង្រឹងមុខងារប្រព័ន្ធ i-PIM ដោយមុខងារស្នូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងបន្ថែមមុខងារគាំទ្រ, ២-អភិវឌ្ឍប្រព័ន្ធថ្មី SNA-PIMS, ៣-អភិវឌ្ឍនិងពង្រឹងមុខងារប្រព័ន្ធ PPDMS និង ៤-អភិវឌ្ឍនិងពង្រឹងមុខងារប្រព័ន្ធ DI-PIMS។
- អភិវឌ្ឍសន្ទានកម្មរវាងប្រព័ន្ធ i-PIM និងប្រព័ន្ធ PPDMS, DI-PIMS, SNA-PIMS ព្រមទាំងសិក្សាលទ្ធភាពសន្ទានកម្មរវាងប្រព័ន្ធស្នូលជាមួយប្រព័ន្ធ FMIS, BPS, SARMIS, DMFAS និងប្រព័ន្ធពាក់ព័ន្ធនៅតាមក្រសួង-ស្ថាប័ន ឬអង្គភាពសាធារណៈផ្សេងទៀត។
- ពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធ i-PIM ទៅកាន់គ្រប់ម្ចាស់គម្រោងនៅរដ្ឋបាលថ្នាក់ជាតិ និងចាប់ផ្ដើមការប្រើប្រាស់ i-PIM នេះជាមួយម្ចាស់គម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៤.៣. ការរៀបចំតម្រូវការថវិកាគាំទ្រ

ដើម្បីអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មនេះឱ្យទទួលបានជោគជ័យ គឺត្រូវការចាំបាច់នូវធនធានមនុស្ស និងធនធានថវិកា សម្រាប់គាំទ្រដល់តួអង្គពាក់ព័ន្ធសំខាន់ៗ នៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដើម្បីធ្វើការអភិវឌ្ឍ កែលម្អ និងធ្វើប្រតិបត្តិការប្រព័ន្ធឌីជីថល ទាំងប្រព័ន្ធដែលត្រូវបង្កើតថ្មី និងប្រព័ន្ធដែលមានស្រាប់ ជាពិសេសការអភិវឌ្ឍប្រព័ន្ធ i-PIM ដែល ជាប្រព័ន្ធថ្មី និងជាគ្រឹះ នៃប្រព័ន្ធស្នូលនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ តួអង្គពាក់ព័ន្ធនៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថល អាចរៀបចំ និងលើកសំណើតម្រូវការថវិការៀងៗខ្លួន ផ្អែកទៅតាមតួនាទីនិងភារកិច្ចដែលមានកំណត់នៅក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលនេះ។

ការរៀបចំតម្រូវការថវិកា គឺអាចបែងចែកជាផ្នែកៗដូចតទៅ៖ ការអភិវឌ្ឍប្រព័ន្ធថ្មី (New System Development), ការកែលម្អប្រព័ន្ធដែលមានស្រាប់ (System Enhancement), សន្ទានកម្មប្រព័ន្ធនិងប្រព័ន្ធ (System Interfacing/Integration), ការរៀបចំទិន្នន័យដំបូងដាក់ចូលប្រព័ន្ធ (Data Migration), ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT Infrastructure Preparation), អាជ្ញាបណ្ណកម្មវិធីគាំទ្រដំណើរការប្រព័ន្ធ (Software Licensing), ការពង្រឹងប្រព័ន្ធសន្តិសុខសាយប័រ (Cybersecurity), ការបណ្តុះបណ្តាល និងកម្មវិធីគ្រប់គ្រងការផ្លាស់ប្តូរ (Capacity Building/Change Management), ការថែទាំ និងគាំទ្រប្រតិបត្តិការប្រព័ន្ធ (Maintenance and Support), ការគាំទ្រគម្រោងនិងកិច្ចការទូទៅ (Project Management and Coordination) និងកិច្ចការផ្សេងៗទៀតដែលមិនបានគ្រោងទុក។

## ៤.៤. ហានិភ័យ

| ហានិភ័យ | កម្រិត | យុទ្ធសាស្ត្រកាត់បន្ថយ |
| --- | --- | --- |
| បញ្ហាការសម្របសម្រួលតួអង្គពាក់ព័ន្ធ (តួអង្គច្រើន ប្រព័ន្ធផ្សេងគ្នា និងមានការងារខុសគ្នា) | ខ្ពស់ | - ប្រើប្រាស់យន្តការគណៈកម្មការវិនិយោគសាធារណៈ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានស្រាប់ ក្នុងការសម្របសម្រួល តម្រង់ទិស និងជំរុញការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ពីគ្រប់សមាសភាពនិងភាគីពាក់ព័ន្ធ<br>- អាចមានកិច្ចប្រជុំតាមដានវឌ្ឍនភាពនិងបញ្ហាប្រឈមការងារជាប្រចាំ (ត្រីមាស)។ |
| ការប្រឆាំងនឹងការផ្លាស់ប្តូររបៀបធ្វើការថ្មី ជាពិសេសការផ្លាស់ប្តូរទៅតាមឌីជីថលទាំងស្រុង | ខ្ពស់ | - អនុវត្តកម្មវិធីគ្រប់គ្រងការផ្លាស់ប្តូរ និងរៀបចំការបណ្តុះបណ្តាលអ្នកប្រើប្រាស់<br>- មានសេវាគាំទ្រការប្រើប្រាស់ប្រព័ន្ធល្អ។ |
| បញ្ហាធនធានមនុស្សផ្នែកបច្ចេកទេសនៅតាមក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធដែលត្រូវការអភិវឌ្ឍប្រព័ន្ធថ្មី ឬកែលម្អប្រព័ន្ធ | ខ្ពស់ | - បញ្ហាធនធានមនុស្សផ្នែកបច្ចេកទេសនៅតាមក្រសួង-ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធដែលត្រូវការអភិវឌ្ឍប្រព័ន្ធថ្មី ឬកែលម្អប្រព័ន្ធ |
| ភាពស្មុគស្មាញផ្នែកបច្ចេកទេសសន្ទានកម្មប្រព័ន្ធ | មធ្យម | - ប្រើប្រាស់ស្តង់ដា API<br>- អនុលោមតាមក្របខ័ណ្ឌអន្តរប្រតិបត្តិការគោលនៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ។ |
| បញ្ហាប្រឈមផ្នែកសន្តិសុខសាយប័រ និងឯកជនភាពនៃទិន្នន័យ | មធ្យម | - ដំឡើងឧបករណ៍សន្តិសុខសាយប័រសម្រាប់ប្រព័ន្ធផ្ទាល់មួយចំនួន<br>- ភ្ជាប់ទៅកាន់មជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខ ក.ស.ហ.វ. ដើម្បីជួយពិនិត្យ និងតាមដានជាប្រចាំ។ |
| បញ្ហាផ្នែកគុណភាព និងស្តង់ដារទិន្នន័យ ដោយសារអសង្គតិភាពនៃការប្រើប្រាស់ទិន្នន័យបច្ចុប្បន្ន | មធ្យម | - ពង្រឹងក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ<br>- ពង្រឹងក្របខ័ណ្ឌនៃការត្រួតពិនិត្យគុណភាពទិន្នន័យ<br>- រៀបចំនិងអនុវត្តស្តង់ដារទិន្នន័យ, បញ្ជីទិន្នន័យ និងលក្ខខណ្ឌនៃការពិនិត្យទិន្នន័យ<br>- ចាត់តាំងអ្នកទទួលបន្ទុកផ្នែកគ្រប់គ្រងទិន្នន័យនៅតាមអង្គភាពនីមួយៗ។ |
| បញ្ហាកង្វះថវិកា | មធ្យម | - រៀបចំផែនការថវិកាជាជំហានៗ និងតាមឆ្នាំ<br>- ស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍លើចំណែកណាមួយនៃគម្រោង។ |

*តារាង 1. ហានិភ័យនៃការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្ម*

## ៤.៥. យន្តការសម្របសម្រួល តាមដាន និងវាយតម្លៃ

ការសម្របសម្រួល តាមដាន និងជំរុញការអនុវត្ត**ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ** គឺអាចប្រើប្រាស់យន្តការដែលស្ថិតក្នុងក្របខ័ណ្ឌគណៈកម្មការវិនិយោគសាធារណៈ និងគណៈកម្មាធិការដឹកនាំកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានស្រាប់ ដោយអាចបង្កើតឱ្យមានក្រុមការងារបច្ចេកទេសចំពោះកិច្ចតាមការចាំបាច់ជាក់ស្តែង សម្រាប់ការសម្របសម្រួលផ្ទៃក្នុង ក.ស.ហ.វ. ។

ក្នុងន័យនេះ, អគ្គនាយកដ្ឋាន ឬអង្គភាពពាក់ព័ន្ធនីមួយៗនៃ ក.ស.ហ.វ. រួមទាំង ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាចរៀបចំ និងដាក់បញ្ចូលផែនការសកម្មភាពសម្រាប់ការចូលរួមអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលនេះ ទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលស្ថិតនៅក្រោមការសម្របសម្រួល តាមដាន និងវាយតម្លៃដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការរៀបចំផែនការសកម្មភាពនេះ, ក៏អាចដាក់ស្នើការពិភាក្សា និងពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល និងអគ្គនាយកដ្ឋានគោលនយោបាយនៃ ក.ស.ហ.វ. ដែលទទួលបន្ទុកសម្របសម្រួលការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មនេះផ្ទាល់ផងដែរ។ ទន្ទឹមនេះ, សកម្មភាពគន្លឹះៗនៃក្របខ័ណ្ឌនិម្មាបនកម្មនេះ ក៏បានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធវិនិយោគសាធារណៈរបស់កម្ពុជា ដែលមានការតាមដាន និងវាយតម្លៃដោយឡែកលើការអនុវត្តបច្ចុប្បន្នកម្មយុទ្ធសាស្ត្រនេះ នៅក្រោមឆ័ត្រនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ។

អគ្គនាយកដ្ឋានពាក់ព័ន្ធនៃ ក.ស.ហ.វ. ដែលចូលរួមអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មនេះ ក៏អាចនឹងត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំតាមដាន និងពិនិត្យលទ្ធផលនៃការអនុវត្តក្របខ័ណ្ឌនេះ តាមការចាំបាច់ពីអង្គភាពដែលមានភារកិច្ចសម្របសម្រួលការអភិវឌ្ឍ និងការដាក់ដំណើរការប្រព័ន្ធអេកូឡូស៊ីឌីជីថល ដើម្បីពិនិត្យលើលទ្ធផលការងាររួម និងពិភាក្សាដោះស្រាយនូវបញ្ហាប្រឈមនានា ដែលអាចកើតមាននៅក្នុងការអនុវត្តជាក់ស្តែង។

# ៥. សេចក្តីសន្និដ្ឋាន

**ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ** ត្រូវបានរៀបចំឡើងដោយមានការសិក្សាស្វែងយល់យ៉ាងល្អិតល្អន់ ទៅលើស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដែលមានទាំងក្របខ័ណ្ឌគោលនយោបាយនិងគតិយុត្ត, វដ្តគម្រោងវិនិយោគសាធារណៈ, ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការចុះជួបពិភាក្សាផ្ទាល់ជាមួយតួអង្គដែលមានការពាក់ព័ន្ធសំខាន់ៗ។ ក្របខ័ណ្ឌនិម្មាបនកម្មនេះ ផ្តល់ជាពុម្ពយុទ្ធសាស្ត្រមួយសម្រាប់ការធ្វើទំនើបកម្ម និងការធ្វើឌីជីថលូបនីយកម្មការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅកម្ពុជា ព្រមទាំងផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការកសាងប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដែលមានសមាហរណកម្ម, តម្លាភាព, គណនេយ្យភាព និងមានទិន្នន័យគោលច្បាស់លាស់ គាំទ្រដល់ការសម្រេចចិត្តដោយផ្អែកលើទិន្នន័យ, បង្កើនភាពប្រទាក់ក្រឡានិងទំនាក់ទំនងគ្នារវាងតួអង្គពាក់ព័ន្ធ និងពង្រឹងអភិបាលកិច្ចនៅដំណាក់កាលនីមួយៗនៃវដ្តគម្រោងវិនិយោគសាធារណៈ។

ក្របខ័ណ្ឌនិម្មាបនកម្មនេះ រំពឹងថានឹងអាចដោះស្រាយបញ្ហាប្រឈមដែលកំពុងជួបប្រទះនាពេលបច្ចុប្បន្ន ព្រមទាំងបង្កើតបាននូវមូលដ្ឋានគ្រឹះសម្រាប់ជំរុញបង្កើនប្រសិទ្ធភាពការងារសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។ ក្របខ័ណ្ឌនេះ បានកំណត់យ៉ាងច្បាស់នូវចក្ខុវិស័យ, វិធានការគន្លឹះ, គោលការណ៍និងអភិក្រម, តួនាទីរបស់តួអង្គពាក់ព័ន្ធនីមួយៗ និងសំណុំនៃប្រព័ន្ធឌីជីថលដែលស្ថិតនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថល សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ព្រមទាំងបានតម្រង់ទិសសម្រាប់ការអនុវត្តក្នុងរយៈពេល ៤ ឆ្នាំគិតពីឆ្នាំ ២០២៥ ដល់ឆ្នាំ ២០២៨។

ជាមួយគ្នានេះ, ភាពជោគជ័យនៃការអនុវត្តក្របខ័ណ្ឌនេះ ទាមទារចាំបាច់នូវការគាំទ្រពីថ្នាក់ដឹកនាំនយោបាយ, ការគាំទ្រធនធានថវិកា, ការសម្របសម្រួល ការចូលរួម និងកិច្ចសហប្រតិបត្តិការខ្ពស់ពីគ្រប់តួអង្គពាក់ព័ន្ធ ជាពិសេសតួអង្គនៅក្នុង ក.ស.ហ.វ. និងតួអង្គជាក្រសួង-ស្ថាប័ន ឬអង្គភាពសាធារណៈដែលជាម្ចាស់គម្រោង។ ការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មនេះ នឹងជំរុញការផ្លាស់ប្តូររបៀបរបបធ្វើការតាមបែបឌីជីថលទាំងស្រុងក្នុងដំណើរការនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ គិតចាប់ពីដំណាក់កាលដំបូង នៃវដ្តគម្រោងវិនិយោគសាធារណៈ គឺការធ្វើអត្តសញ្ញាណកម្ម និងការរៀបចំសំណើគម្រោង រហូតដល់ដំណាក់កាលចុងក្រោយនៃវដ្តគម្រោងវិនិយោគសាធារណៈ គឺការវាយតម្លៃបញ្ចប់គម្រោង ដោយធានាថាទិន្នន័យមានរំហូរប្រកបដោយប្រសិទ្ធភាពរវាងអង្គភាព ឬស្ថាប័ន, ទិន្នន័យមានសង្គតិភាពនិងអាចប្រើប្រាស់បានរួមគ្នា ហើយទិន្នន័យអាចធ្វើអន្តរប្រតិបត្តិការពេញលេញរវាងប្រព័ន្ធនីមួយៗ នៅក្រោមឆ័ត្រនៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។

ជារួម, ក្របខ័ណ្ឌនិម្មាបនកម្មនេះ នឹងចូលរួមចំណែកធំមួយ សម្រាប់ការសម្រេចបានគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤, គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥ និងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥ ព្រមទាំង គាំទ្រដល់ចក្ខុវិស័យរបស់កម្ពុជាក្នុងការកសាងរដ្ឋបាលសាធារណៈទំនើប ប្រកបដោយបរិយាប័ន្ន និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដែលមានស្រាប់ឱ្យអស់សក្តានុពល៕

# ៦. ឧបសម្ព័ន្ធ

- យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា
- កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល
- ផែនការអភិវឌ្ឍ និងកម្មវិធីនិយោគបីឆ្នាំរំកិលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម
- ចក្ខុវិស័យ និង យុទ្ធសាស្ត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤
- យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥
- យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥
- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥
- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥
- ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ
- ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- អនុក្រឹត្យស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ
- អនុក្រឹត្យស្តីពីកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល
- អនុក្រឹត្យស្តីពីកម្មវិធីវិនិយោគនិងអភិវឌ្ឍ ៣ឆ្នាំរំកិលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក
- អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ
- ប្រកាសស្តីពីការបង្កើតគណៈកម្មាធិការវិនិយោគសាធារណៈ
- ប្រកាសស្តីពីគោលការណ៍រួមសម្រាប់ការគ្រប់គ្រងគម្រោងថៃទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។

## ឧបសម្ព័ន្ធទី ២៖ ក្របខ័ណ្ឌអន្តរប្រតិបត្តិការ

**ទិដ្ឋភាពទូទៅ៖** ក្របខ័ណ្ឌអន្តរប្រតិបត្តិការ គឺជាធាតុសំខាន់មួយនៃ**ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេឡិចត្រូនិចសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ** ដោយនឹងផ្តល់នូវស្តង់ដា យន្តការ និងអភិបាលកិច្ច សម្រាប់ការផ្លាស់ប្តូរទិន្នន័យ និងការសម្របសម្រួល ការធ្វើសន្ទានកម្មរវាងប្រព័ន្ធនិងប្រព័ន្ធក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ ការធ្វើអន្តរប្រតិបត្តិការ នឹងធានាថាប្រព័ន្ធដែលអភិវឌ្ឍដោយអង្គភាព ឬស្ថាប័នផ្សេងគ្នា អាចទំនាក់ទំនងចែករំលែកទិន្នន័យ ព្រមទាំងដំណើរការជាប្រព័ន្ធអេកូឡូស៊ីឌីជីថលដែលស៊ីសង្វាក់គ្នា មានសង្គតិភាព សុវត្ថិភាព និងគណនេយ្យភាពលើទិន្នន័យ។ ការរៀបចំសេចក្តីលម្អិតអំពីអន្តរប្រតិបត្តិការប្រព័ន្ធនឹងត្រូវធ្វើឡើងក្នុងដំណាក់កាលអភិវឌ្ឍន៍ប្រព័ន្ធ។

**គោលបំណង៖** ១-ធ្វើឱ្យមានការចែករំលែក និងធ្វើសមាហរណកម្មទិន្នន័យរវាងប្រព័ន្ធទាំងអស់ដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគសាធារណៈទាំងក្នុង និងក្រៅ ក.ស.ហ.វ., ២- លើកកម្ពស់សង្គតិភាពផ្នែកបច្ចេកទេស តាមរយៈការប្រើប្រាស់ស្តង់ដាទិន្នន័យនិងពិធីសារ និងការកំណត់និយមន័យនៃមេតាទិន្នន័យ, ៣-ធានាអន្តរប្រតិបត្តិការរវាងស្ថាប័ន តាមរយៈអភិបាលកិច្ច, តួនាទី និងយន្តការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធ។

**គោលការណ៍៖** ជាគោលការណ៍, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់ដែលស្ថិតនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ត្រូវរៀបចំផ្នែកអន្តរប្រតិបត្តិការទៅតាមគោលការណ៍ដែលមានចែងនៅក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ.។ បន្ថែមលើគោលការណ៍ដែលមានចែង, ការធ្វើអន្តរប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌនេះ ត្រូវតែប្រើប្រាស់លេខអត្តសញ្ញាណសម្គាល់គម្រោងរួមតែមួយ (Unique Project ID) និងត្រូវមានមុខងារជូនដំណឹងសម្រាប់ផ្តល់ព័ត៌មានបច្ចុប្បន្នភាពពាក់ព័ន្ធនឹងស្ថានភាពរបស់គម្រោង។




*រូបភាព 7. ក្របខ័ណ្ឌអន្តរប្រតិបត្តិការ (ដកស្រង់ពីក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ.)*

**ស្រទាប់នៃអន្តរប្រតិបត្តិការះ** ត្រូវបានកំណត់ជា ៤ ស្រទាប់គឺ ១-ស្រទាប់បច្ចេកទេស, ២- ស្រទាប់អត្ថន័យ, ៣-ស្រទាប់ស្ថាប័ន/អង្គភាព និង ៤-ស្រទាប់គតិយុត្តនិងគោលនយោបាយ។

1- ស្រទាប់បច្ចេកទេស (Technical)៖ រៀបចំនូវស្តង់ដានិងពិធីសារបច្ចេកទេស ដូចជា API, Web Services, ច្រកផ្លាស់ប្តូរទិន្នន័យ, CamDX, ទម្រង់ទិន្នន័យ XML/JSON។ល។

2- ស្រទាប់អត្ថន័យ (Semantic)៖ កំណត់អត្ថន័យ និងការពន្យល់ឱ្យដូចគ្នាលើទិន្នន័យដែលត្រូវផ្លាស់ប្តូរគ្នា តាមរយៈការរៀបចំវចនានុក្រមទិន្នន័យ (Data Dictionaries), បញ្ជីលេខកូដរួម, ស្តង់ដាមេតាទិន្នន័យ, ទិន្នន័យគោល ជាដើម។

3- ស្រទាប់ស្ថាប័ន/អង្គភាព (Organizational)៖ កំណត់ថាស្ថាប័ន/អង្គភាពសម្របសម្រួលយ៉ាងណាទៅលើនីតិវិធី, តួនាទី និងការទទួលខុសត្រូវលើការចែករំលែកទិន្នន័យ ដូចជាការរៀបចំនិយាមប្រតិបត្តិស្តង់ដា (SOP), កិច្ចព្រមព្រៀងចែករំលែកទិន្នន័យ, តួនាទីលើទិន្នន័យ ដែលជាចំណែកនៃអភិបាលកិច្ចទិន្នន័យ។

4 ស្រទាប់គតិយុត្តនិងគោលនយោបាយ (Legal and Policy)៖ ធានាថាការផ្លាស់ប្តូរទិន្នន័យ និងការធ្វើសន្ទានកម្មប្រព័ន្ធ អនុលោមទៅតាមលិខិតបទដ្ឋានគតិយុត្តដែលមានចែងទាំងទាំងក្នុង ក.ស.ហ.វ. និងក្នុងកម្រិតរាជរដ្ឋាភិបាល ដែលមានដូចជាគោលនយោបាយឯកជនភាពនៃទិន្នន័យ, ស្តង់ដាទិន្នន័យ, ចំណាត់ថ្នាក់ទិន្នន័យ ជាដើម។

**សមាសធាតុនៃអន្តរប្រតិបត្តិការះ** មានដូចជា ១-ប្រព័ន្ធសមាហរណកម្មទិន្នន័យកណ្តាល, ២-ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ៣-ការគ្រប់គ្រង API, ៤-កន្លែងផ្ទុកទិន្នន័យគោល និងមេតាទិន្នន័យ និង ៥-

1- ប្រព័ន្ធសមាហរណកម្មកណ្តាល (i-PIM)៖ មានតួនាទីជាប្រព័ន្ធទិន្នន័យគោល និងជាប្រព័ន្ធសម្របសម្រួលជាមួយប្រព័ន្ធនានា នៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។

2- ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)៖ ជាហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រឹះដែលនឹងសម្រួលលើស្តង់ដា និងសុវត្ថិភាពនៃការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធនិងប្រព័ន្ធ។

3- ការគ្រប់គ្រង API៖ ផ្តល់កន្លែងសម្រាប់ការគ្រប់គ្រងនិងត្រួតពិនិត្យលើការប្រើប្រាស់ API រវាងប្រព័ន្ធនិងប្រព័ន្ធ។

4- កន្លែងផ្ទុកទិន្នន័យគោល និងមេតាទិន្នន័យ (Metadata and Master Data Repository)៖ រក្សានូវនិយមន័យ, ចំណាត់ថ្នាក់ និងកូដយោង សម្រាប់ទិន្នន័យដែលប្រើរួម។

5- ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ៖ ធានានូវអនុលោមភាពផ្អែកតាមគោលនយោបាយដែលមានចែង និងគណនេយ្យភាពទៅលើគុណភាព និងការប្រើប្រាស់ទិន្នន័យ។

**ម៉ូដែលនៃការធ្វើសន្ទានកម្មៈ** មានដូចជា ១-សន្ទានកម្មរវាងប្រព័ន្ធនៅក្នុង ក.ស.ហ.វ., ២-សន្ទានកម្មអន្តរក្រសួង-ស្ថាប័នរដ្ឋ និង ៣-សន្ទានកម្មរវាងប្រព័ន្ធ ក.ស.ហ.វ. ជាមួយស្ថាប័នក្រៅពីរដ្ឋ។

1- សន្ទានកម្មរវាងប្រព័ន្ធនៅក្នុង ក.ស.ហ.វ. (Intra-Ministry System Interfacing)៖ ជាការធ្វើសន្ទានកម្មរវាងប្រព័ន្ធពាក់ព័ន្ធនៅក្នុង ក.ស.ហ.វ. ជាពិសេស i-PIM, PPP-PIMS, DI-PIMS, PPDMS, SNA-PIMS, FMIS, BPS, SARMIS។
2- សន្ទានកម្មរវាងប្រព័ន្ធអន្តរក្រសួង-ស្ថាប័នរដ្ឋ (Inter-Ministry System Interfacing)៖ ជាការធ្វើសន្ទានកម្មរវាងប្រព័ន្ធរបស់ ក.ស.ហ.វ. ជាមួយក្រសួង- ស្ថាប័នរដ្ឋផ្សេងទៀត ដូចជាប្រព័ន្ធរបស់ក្រសួងផែនការ, ប្រព័ន្ធរបស់ក្រសួងមហាផ្ទៃ, ជាដើម។
3- សន្ទានកម្មរវាងប្រព័ន្ធ ក.ស.ហ.វ. ជាមួយស្ថាប័នក្រៅពីរដ្ឋ (External System Interfacing)៖ ជាការធ្វើសន្ទានកម្មរវាងប្រព័ន្ធរបស់

**តួនាទីនិងភារកិច្ចតួអង្គពាក់ព័ន្ធៈ**

*ក្រសួង-ស្ថាប័ន ឬអង្គភាពសំខាន់ៗនៃ ក.ស.ហ.វ. ដែលពាក់ព័ន្ធគម្រោងវិនិយោគសាធារណៈ៖*

- ចាត់តាំងក្រុមការងារឱ្យបានច្បាស់លាស់ សម្រាប់ចូលរួមគាំទ្រនៅក្នុងការធ្វើអន្តរប្រតិបត្តិការរវាងប្រព័ន្ធរបស់ខ្លួន ជាមួយប្រព័ន្ធកណ្តាល។
- ត្រូវផ្តល់នូវឯកសារណែនាំអំពីរបៀបប្រើប្រាស់ API ដោយប្រើប្រាស់កម្មវិធីដូចជា Swagger ឬ Postman ជាដើម ដើម្បីឱ្យអ្នកអភិវឌ្ឍកម្មវិធីអាចយល់ពី APIs បានងាយស្រួល។
- ត្រូវធានាថាប្រព័ន្ធខ្លួន អាចទាញយកបាននូវលេខសម្គាល់អត្តសញ្ញាណគម្រោង និងទិន្នន័យពាក់ព័ន្ធនឹងគម្រោងតាមតម្រូវការរវាងគ្នា។
- គប្បីធ្វើតេស្តការដាក់ឱ្យប្រើប្រាស់ API នៅក្នុងបរិស្ថានសាកល្បងឱ្យបានហ្មត់ចត់ និងរួចរាល់ ដើម្បីធានាបានថាការកំណត់មុខងារផ្សេងៗដំណើរការល្អដូចការរំពឹងទុក។
- ត្រូវទទួលខុសត្រូវលើគុណភាពទិន្នន័យរបស់ខ្លួនក្នុងនាមជាម្ចាស់ទិន្នន័យ មុនធ្វើការផ្លាស់ប្តូរ។

*អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលនៃ ក.ស.ហ.វ.៖*

- កំណត់នូវស្តង់ដាររួមក្នុងការរៀបចំ អភិវឌ្ឍ និងថែទាំ API ស្របតាមឧត្តមានុវត្តន៍ និងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ. ដើម្បីធានានូវការជឿទុកចិត្ត, ការពង្រីកបន្ថែមបាន និងងាយស្រួលក្នុងការប្រើប្រាស់សម្រាប់តួអង្គពាក់ព័ន្ធ។
- ត្រូវមានយន្តការការងារច្បាស់លាស់ក្នុងការថែទាំ និងរក្សាទុកទិន្នន័យគោលរបស់គម្រោងនៅក្នុងប្រព័ន្ធ i-PIM និងសម្របសម្រួលរៀបចំឯកសារលម្អិតពីអន្តរប្រតិបត្តិការទិន្នន័យ។
- គាំទ្រ និងសម្របសម្រួលជាប្រចាំក្នុងការតភ្ជាប់បញ្ចូលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធនានាទៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈជាពិសេសការភ្ជាប់សន្ទានកម្មជាមួយប្រព័ន្ធ i-PIM ដែលខ្លួនគ្រប់គ្រង។

## ឧបសម្ព័ន្ធទី ៣៖ ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ

**ទិដ្ឋភាពទូទៅ៖** ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ក៏ជាសមាសធាតុសំខាន់នៃក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ ក្របខ័ណ្ឌនេះ តម្រង់ទិសក្នុងការរៀបចំជាគោលការណ៍, រចនាសម្ព័ន្ធ, ដំណើរការ និងទំនួលខុសត្រូវលើទិន្នន័យ ដើម្បីធានាថាទិន្នន័យដែលប្រមូល, រក្សាទុក និងចែករំលែកនៅក្នុងប្រព័ន្ធឌីជីថលមានគុណភាព មានសុវត្ថិភាព និងមានការប្រើប្រាស់ត្រឹមត្រូវ។ ប្រសិទ្ធភាពនៃអភិបាលកិច្ចទិន្នន័យ មានសារៈសំខាន់ក្នុងការសម្រេចបាននូវ សុចរិតភាព, តម្លាភាព, ទំនួលខុសត្រូវ និងការជឿទុកចិត្តលើទិន្នន័យ ដែលចាំបាច់ណាស់សម្រាប់គាំទ្រដល់ការសម្រេចចិត្តដោយផ្អែកលើទិន្នន័យ និងការសម្របសម្រួលស្ថាប័នប្រកបដោយប្រសិទ្ធភាពក្នុងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ ការរៀបចំសេចក្ដីលម្អិតអំពីអភិបាលកិច្ចទិន្នន័យនឹងត្រូវធ្វើឡើងក្នុងដំណាក់កាលអភិវឌ្ឍន៍និងធ្វើប្រតិបត្តិការប្រព័ន្ធ។

**គោលបំណង៖** ១-ធានាគុណភាព, សង្គតិភាព និងភាពជឿជាក់លើទិន្នន័យ សម្រាប់គ្រប់ប្រព័ន្ធនិងអង្គភាពនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថល, ២-កំណត់តួនាទី និងទំនួលខុសត្រូវឱ្យបានច្បាស់របស់តួអង្គពាក់ព័ន្ធនឹងទិន្នន័យនីមួយៗ ទាំងម្ចាស់ទិន្នន័យ, អ្នកគ្រប់គ្រងទិន្នន័យ, អ្នកប្រើប្រាស់ទិន្នន័យ ជាដើម, ៣-លើកកម្ពស់សុវត្ថិភាព, ឯកជនភាព និងក្រមសីលធម៌នៃការប្រើប្រាស់លើទិន្នន័យ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ, ៤-សម្រួលដល់ការចែករំលែក និងការប្រើប្រាស់ទិន្នន័យឡើងវិញ។

**គោលការណ៍៖** អនុលោមតាមគោលការណ៍ដែលមានចែងនៅក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ. ពាក់ព័ន្ធនឹងតួនាទី និងទំនួលខុសត្រូវលើទិន្នន័យ។ បន្ថែមលើគោលការណ៍ដែលមានចែង, ក្របខ័ណ្ឌនេះបានរំលេចនូវគោលការណ៍ជាក់លាក់មួយចំនួនទៅលើទិន្នន័យគឺ គណនេយ្យភាព, គុណភាព, តម្លាភាព, សុវត្ថិភាព និងឯកជនភាព, អន្តរប្រតិបត្តិការ និងការប្រើប្រាស់ឡើងវិញ, ក្រមសីលធម៌នៃការប្រើប្រាស់ និងនិរន្តរភាព។

- គណនេយ្យភាព៖ កំណត់ច្បាស់ពីភាពជាម្ចាស់ និងអ្នកគ្រប់គ្រងលើគ្រប់ទិន្នន័យ ដោយធានានូវការតាមដានការផ្លាស់ប្ដូរ និងការប្រើប្រាស់។
- គុណភាព៖ ទិន្នន័យត្រូវតែមានសុក្រឹតភាព, ភាពពេញលេញ, សង្គតិភាព និងទាន់ពេល។
- តម្លាភាព៖ គោលនយោបាយទិន្នន័យ, សិទ្ធិចូលប្រើ និងដំណើរការប្រើប្រាស់ត្រូវតែមានភាពច្បាស់លាស់ អាចបង្ហាញបាន និងអាចយល់បានសម្រាប់អ្នកពាក់ព័ន្ធដែលអនុញ្ញាត។
- សុវត្ថិភាព និងឯកជនភាព៖ ទិន្នន័យត្រូវតែទទួលបានការការពារ និងទប់ទល់ការចូលប្រើដោយគ្មានការអនុញ្ញាត, ការបញ្ចេញ ឬការកែប្រែ ដោយធានាអនុលោមភាពតាមបទប្បញ្ញត្តិសន្តិសុខឌីជីថលរបស់ជាតិ។
- អន្តរប្រតិបត្តិការ និងការប្រើប្រាស់ឡើងវិញ៖ ទិន្នន័យត្រូវមានកំណត់ស្តង់ដារ និងចែករំលែករវាងគ្នាតាមតម្រូវការ តាមរយៈទម្រង់រួម និងកូដយោងតែមួយ។
- ក្រមសីលធម៌នៃការប្រើប្រាស់ទិន្នន័យ៖ ការប្រើប្រាស់ទិន្នន័យត្រូវតែដើម្បីបម្រើប្រយោជន៍រួម មានភាពស្របច្បាប់ និងគាំទ្រគោលបំណងនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។
- និរន្តរភាព៖ ដំណើរការនៃអភិបាលកិច្ចទិន្នន័យត្រូវតែធ្វើស្ថាប័ននីយកម្ម ដើម្បីធានាការបន្តកិច្ចការនេះជានិរន្ត លើសពីការធ្វើសម្រាប់តែគម្រោងឬប្រព័ន្ធមួយៗ។

**រចនាសម្ព័ន្ធអភិបាលកិច្ចទិន្នន័យ៖** កំណត់ពីតួនាទី និងទំនួលខុសត្រូវរបស់តួអង្គពាក់ព័ន្ធ សម្រាប់ធានាគុណភាព សុចរិតភាព និងសុវត្ថិភាពទិន្នន័យនៃប្រព័ន្ធអេកូឡូស៊ីឌីជីថលគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដោយអនុវត្តតាមមុខងារអភិបាលកិច្ចសំខាន់ៗចំនួន ៤ ដូចខាងក្រោម៖

- ប្រធានទិន្នន័យ (Data Owner) រួមមាន ស្ថាប័ន ឬអង្គភាពជាម្ចាស់គម្រោង (Project Owner), អគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ. (មានដូចជា GDB-DI, GDICDM, GDPPP, GDSNAF, GDP)។ ប្រធានទិន្នន័យ គឺជាស្ថាប័ន ឬអង្គភាពដែលទទួលខុសត្រូវលើខ្លឹមសារ, អត្ថន័យ និងគុណភាពទិន្នន័យ និងផ្តល់ការយល់ព្រមសម្រាប់ការចែករំលែកទិន្នន័យទៅបុគ្គលផ្សេង។ ក្នុងន័យនេះ, បើទោះបីទិន្នន័យបានធ្វើសន្ទានកម្មជាមួយប្រព័ន្ធកណ្តាល ឬប្រព័ន្ធណាមួយ ក៏ប្រធានទិន្នន័យនៅតែជាអ្នកគ្រប់គ្រងទិន្នន័យរបស់ខ្លួនបានដដែល តាមរយៈការប្រើប្រាស់ផតថលរួម។
- បុគ្គលអធិការកិច្ចទិន្នន័យ (Data Steward) រួមមាន អធិការកិច្ចទិន្នន័យនៃអគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ., អធិការកិច្ចទិន្នន័យនៃ អ.ស.ឧ. និងអធិការកិច្ចទិន្នន័យនៃអង្គភាពជាម្ចាស់គម្រោង។ ដូចនេះ, តួអង្គពាក់ព័ន្ធត្រូវចាត់តាំងឱ្យបានច្បាស់លាស់នូវបុគ្គលអធិការកិច្ចទិន្នន័យរបស់ខ្លួន ដើម្បីពិនិត្យ និងធានាគុណភាពទិន្នន័យនៃគម្រោងវិនិយោគនៅក្នុងប្រព័ន្ធ។
- បុគ្គលគ្រប់គ្រងទិន្នន័យ (Data Custodian) រួមមាន អ.ស.ឧ. គ្រប់គ្រងប្រព័ន្ធ i-PIM, ក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន ក.ស.ហ.វ. គ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ, អគ្គនាយកដ្ឋានសំខាន់ៗនៃ ក.ស.ហ.វ. គ្រប់គ្រងប្រព័ន្ធនៅតាមអង្គភាពសាមី។
- បុគ្គលប្រើប្រាស់ទិន្នន័យ (Data Consumer) សំដៅដល់គ្រប់តួអង្គដែលទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់ទិន្នន័យតាមការស្នើសុំជាក់ស្តែង។

**សមាសធាតុស្នូលនៃអភិបាលកិច្ចទិន្នន័យ៖** រួមមាន ១-ប្រធានទិន្នន័យ និងបុគ្គលអធិការកិច្ចទិន្នន័យ, ២-ការគ្រប់គ្រងគុណភាពទិន្នន័យ, ៣-មេតាទិន្នន័យ និងទិន្នន័យគោល, ៤) ការត្រួតពិនិត្យសុវត្ថិភាព និងឯកជនភាព, ៥-ការចែករំលែកទិន្នន័យ និងការគ្រប់គ្រងការចូលប្រើ, ៦-ការគ្រប់គ្រងវដ្តនៃទិន្នន័យ និង ៧-ក្របសីលធម៌និងអនុលោមភាពទិន្នន័យ។

**ចំណាត់ថ្នាក់នៃទិន្នន័យ៖**

| ចំណាត់ថ្នាក់ | បរិយាយ | សិទ្ធិចូលប្រើប្រាស់ |
|---|---|---|
| សាធារណៈ | សម្រាប់សម្គាល់លើទិន្នន័យដែលសាធារណជនអាចប្រើប្រាស់បាន ដូចជា បញ្ជីគម្រោង, របាយការណ៍ផ្សព្វផ្សាយ ជាដើម។ | សាធារណជន |
| ផ្ទៃក្នុង | សម្រាប់សម្គាល់ទិន្នន័យដែលចែករំលែកបានតែផ្ទៃក្នុង ក.ស.ហ.វ. ប៉ុណ្ណោះ។ | តម្រូវកំណត់សិទ្ធិ |
| សម្ងាត់ | សម្រាប់សម្គាល់លើទិន្នន័យដែលមានភាពរសើប ឬសម្ងាត់ ដូចជា ព័ត៌មានស្ដីពីកិច្ចសន្យា ជាដើម។ | តម្រូវកំណត់សិទ្ធិ |

*តារាង 2. តារាងចំណាត់ថ្នាក់ទិន្នន័យ*

**ដំណើរការអភិបាលកិច្ចទិន្នន័យ៖** អនុវត្តតាមដំណើរនៃការធ្វើផែនការ, ការអនុវត្ត, ការត្រួតពិនិត្យ និងការកែលម្អជាបន្តបន្ទាប់។

- ការធ្វើផែនការទិន្នន័យ៖ កំណត់ពីតម្រូវការ, ប្រភព និងទំនួលខុសត្រូវលើទិន្នន័យ សម្រាប់ដំណាក់កាលនីមួយៗនៃវដ្តគម្រោង។
- ការប្រមូលទិន្នន័យ៖ ការប្រមូលទិន្នន័យធ្វើឡើងតាមរយៈការបញ្ចូលដោយអ្នកប្រើប្រាស់ ឬការធ្វើសន្ទានកម្មប្រព័ន្ធ។ ទិន្នន័យត្រូវបានពិនិត្យភាពពេញលេញ និងភាពត្រឹមត្រូវមុនបញ្ជូនចូលក្នុងប្រព័ន្ធ។
- ការរក្សាទុកទិន្នន័យ៖ ទិន្នន័យរក្សាទុកនៅក្នុងមូលទិន្នន័យកណ្ដាល ភ្ជាប់ជាមួយនឹងការមេតាទិន្នន័យ និងការគ្រប់គ្រងកំណែប្រែទិន្នន័យ។
- ការចូលប្រើប្រាស់ទិន្នន័យ៖ ផ្ដល់សិទ្ធិចូលប្រើតាមរយៈផតថល, របាយការណ៍ ឬផ្ទាំងវិភាគទិន្នន័យ។
- ការត្រួតពិនិត្យទិន្នន័យ៖ ធ្វើសវនកម្មជាប្រចាំ, ត្រួតពិនិត្យគុណភាព និងពិនិត្យឡើងវិញលើគោលនយោបាយ ដើម្បីធានាអនុលោមភាពនិងការកែលម្អ។

## ឧបសម្ព័ន្ធទី ៤៖ ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ

### *1) តារាងដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ រដ្ឋបាលថ្នាក់ជាតិ*

| ដំណាក់កាល | តួអង្គ | សកម្មភាព |
|---|---|---|
| ទី១ - ការធ្វើអត្តសញ្ញាណកម្ម និងការរៀបចំសំណើគម្រោងបឋម | ម្ចាស់គម្រោង | - កំណត់អត្តសញ្ញាណកម្មគម្រោង,<br>- រៀបចំសំណើគម្រោងបឋម ឬឯកសារទស្សនាទាន និង<br>- ដាក់បញ្ចូលសំណើគម្រោងទៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលរបស់ក្រសួងផែនការ។ |
| ទី២ - ការសិក្សាសមិទ្ធិលទ្ធភាព និងការវាយតម្លៃសំណើគម្រោង | ម្ចាស់គម្រោង | - សិក្សាសមិទ្ធិលទ្ធភាព,<br>- វាយតម្លៃគម្រោងលើទិដ្ឋភាពបច្ចេកទេស តម្លៃ ហានិភ័យ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ច្បាប់ ហេតុប៉ះពាល់បរិស្ថាននិងសង្គម និងយន្តការ និងសមត្ថភាពស្ថាប័នសម្រាប់គ្រប់គ្រងនិងតាមដានការអនុវត្តគម្រោង។ |
| ទី៣ - ការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង | ក.ស.ហ.វ. | - ពិនិត្យផ្ទៀងផ្ទាត់លើការវាយតម្លៃសំណើគម្រោងរបស់ម្ចាស់គម្រោង និង<br>- ធ្វើការរៀបចំបញ្ជីអាទិភាពគម្រោង។ |
| ទី៤ - ការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្ម | ម្ចាស់គម្រោង | - ជ្រើសរើសគម្រោងពីបញ្ជីគម្រោងអាទិភាព<br>- កំណត់ប្រភពហិរញ្ញប្បទាន និង<br>- ធ្វើថវិកានីយកម្ម។ |
| ទី៥ - ការគ្រប់គ្រង និងការអនុវត្តគម្រោង | ម្ចាស់គម្រោង<br>ក.ស.ហ.វ. | - ធានាចំណាយ<br>- អនុវត្តនីតិវិធីលទ្ធកម្ម<br>- គ្រប់គ្រងកិច្ចសន្យា<br>- ដំណើរការទូទាត់ និង<br>- តាមដានវឌ្ឍនភាពនៃការអនុវត្តគម្រោង។ |
| ទី៦ - ការកែសម្រួលគម្រោង | ម្ចាស់គម្រោង<br>ក.ស.ហ.វ. | - កែសម្រួលគម្រោងតាមការចាំបាច់<br>- តាមដានការអនុវត្តគម្រោងសម្រាប់ការផ្ទៀងផ្ទាត់ជាមួយការស្នើសុំកែសម្រួលផែនការអនុវត្តគម្រោង។ |
| ទី៧ - ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ក្រោមគម្រោង | ម្ចាស់គម្រោង | - ពិនិត្យ និងវាយតម្លៃបញ្ចប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ<br>- សម្រេចលើការប្រគល់-ទទួល<br>- ដាក់ឱ្យប្រើប្រាស់និងចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋ។ |
| ទី៨ - ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង | ម្ចាស់គម្រោង | - រៀបចំការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង<br>- រៀបចំរបាយការណ៍លទ្ធផលសម្រេចបាន ទាំងលទ្ធផលសម្រេចបានក្នុងរយៈពេលអនុវត្តគម្រោង និងលទ្ធផលចុងក្រោយ ព្រមទាំងបញ្ហាប្រឈមនៃការអនុវត្តគម្រោង។ |

*តារាង 3. ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ រដ្ឋបាលថ្នាក់ជាតិ*

## 2) តារាងដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ

| ដំណាក់កាល | តួអង្គ | សកម្មភាព |
|---|---|---|
| ទី១ - ការធ្វើអត្តសញ្ញាណកម្មគម្រោង | ម្ចាស់គម្រោង (រដ្ឋបាលថ្នាក់ក្រោមជាតិ) | - កំណត់អត្តសញ្ញាណគម្រោង ដើម្បីរៀបចំជាបញ្ជីគម្រោងបឋម។ |
| ទី២ - ការរៀបចំគម្រោងអាទិភាព | ម្ចាស់គម្រោង | - រៀបចំបញ្ជីគម្រោងអាទិភាពទៅតាមផ្នែក និងដាក់លំដាប់អាទិភាព<br>- សម្រាប់ម្ចាស់គម្រោងជា រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនបញ្ជីគម្រោងវិនិយោគអាទិភាពទៅ "ក្រុមការងាររៀបចំយុទ្ធសាស្ត្រថវិការាជធានី ខេត្ត"។ |
| ទី៣ - ការត្រួតពិនិត្យអនុលោមភាព និងសមាហរណកម្ម | គណៈកម្មាធិការសម្រប សម្រួលបច្ចេកទេសរាជធានី ខេត្ត, ក្រុមប្រឹក្សារាជធានី ខេត្ត និងគណៈអភិបាល រាជធានី ខេត្ត, ក្រុមការងារ រៀបចំផែនការ យុទ្ធសាស្ត្រ ថវិការបស់រាជធានី ខេត្ត | - ពិនិត្យ និងផ្តល់អនុលោមភាពលើការស្នើគម្រោង<br>- ការធ្វើសមាហរណកម្មលើការស្នើគម្រោងអាទិភាពទាំងអស់ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា រាជធានី ខេត្ត ទៅតាមរបាយការណ៍/ចេនាសម្ព័ន្ធថវិកាកម្មវិធី។ |
| ទី៤ - ការជ្រើសរើសការស្នើគម្រោង និងថវិកានីយកម្មគម្រោង | ម្ចាស់គម្រោង, ក្រុមប្រឹក្សារាជធានី ខេត្ត, អង្គភាពនៃ ក.ស.ហ.វ. | - រៀបចំនិងសម្រេចផែនការយុទ្ធសាស្ត្រថវិកា |
| ទី៥ - ការរៀបចំឯកសារគម្រោង និងអនុវត្តគម្រោង | ម្ចាស់គម្រោង, អង្គភាពនៃ ក.ស.ហ.វ. | - រៀបចំឯកសារគម្រោង,<br>- អនុវត្តគម្រោងទៅតាមនីតិវិធីនិងវិធានដែលមានដូចជា ការអនុវត្តថវិកា, ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ, ការតាមដានវឌ្ឍនភាពនៃការអនុវត្តគម្រោង ជាដើម។ |
| ទី៦ - ការកែសម្រួលគម្រោង | ម្ចាស់គម្រោង, អ្នកទទួលការ ឬ អ្នកផ្តល់សេវា ឬ អ្នកផ្គត់ផ្គង់ | - កែសម្រួលកិច្ចសន្យាអនុលោមតាមនីតិវិធី។ |
| ទី៧ - ការចុះបញ្ជី និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ | ម្ចាស់គម្រោង | - ចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋ នូវគម្រោងដែលបានបញ្ចប់។ |
| ទី៨ - ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង | ម្ចាស់គម្រោង | - រៀបចំរបាយការណ៍វាយតម្លៃបញ្ចប់ការអនុវត្តគម្រោង។ |

## ឧបសម្ព័ន្ធទី ៥៖ សេចក្តីសម្រេច ស្តីពី ការបង្កើតក្រុមការងាររៀបចំនិម្មាបនកម្មនិងគម្រោងបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៩៦ សហវ.[illegible]

### សេចក្តីសម្រេច
### ស្តីពី
### ការបង្កើតក្រុមការងាររៀបចំនិម្មាបនកម្មនិងគម្រោងបច្ចេកវិទ្យាព័ត៌មាន នៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំនិងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញប្រកាសលេខ ១៦៤ សហវ.ប្រក.អគប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការវិនិយោគសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១-.**

ត្រូវបានបង្កើត "**ក្រុមការងាររៀបចំនិម្មាបនកម្មនិងគម្រោងបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ**" ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **គង់ ម៉ារី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.) | ប្រធាន |
| ២. ឯកឧត្តម **មាស សុខសេនសាន** | រដ្ឋលេខាធិការ ក.ស.ហ.វ. និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) | អនុប្រធាន |
| ៣. ឯកឧត្តម **ឈួន សំរីទ្ធិ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ. | អនុប្រធាន |
| ៤. ឯកឧត្តម **តាំង ទូនលី** | អគ្គនាយកនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល | អនុប្រធាន |
| ៥. លោក **ខឡៃ ទិចិត្រ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា | អនុប្រធាន |
| ៦. លោក **អៀច សេដ្ឋា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល | សមាជិក |
| ៧. លោក **សារឿន សុភុល** | អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ៨. លោក **ឈាខ យូ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ៩. លោក **ឈឹម សុចរស្មី** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន | សមាជិក |
| ១០. លោក **ឡាយ សុភ័ត្រ្ត** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១១. លោក **ម៉ិន ឆាយ** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |

- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំនិងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញប្រកាសលេខ ១៦៤ សហវ.ប្រក.អគប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការវិនិយោគសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១-.**

ត្រូវបានបង្កើត "**ក្រុមការងាររៀបចំនិម្មាបនកម្មនិងគម្រោងបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ**" ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **គង់ ម៉ារី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.) | ប្រធាន |
| ២. ឯកឧត្តម **មាស សុខសេនសាន** | រដ្ឋលេខាធិការ ក.ស.ហ.វ. និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) | អនុប្រធាន |
| ៣. ឯកឧត្តម **ឈួន សំរិទ្ធិ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ. | អនុប្រធាន |
| ៤. ឯកឧត្តម **តាំង ឧទុនលី** | អគ្គនាយកនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល | អនុប្រធាន |
| ៥. លោក **ខន្តី ទិចិត្រ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា | អនុប្រធាន |
| ៦. លោក **អៀច សេដ្ឋា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល | សមាជិក |
| ៧. លោក **សារឿន សុគុល** | អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ៨. លោក **ឈាង យូ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ៩. លោក **ឈឹម សុចរស្មី** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន | សមាជិក |
| ១០. លោក **ឡាយ សុភ័ក្រ** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១១. លោក **ម៉ិន ឆាយ** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |

| | | |
|---|---|---|
| ១២. លោកស្រី **នន់ ច័ន្ទសុភ័ក្ត្រ** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន | សមាជិក |
| ១៣. លោក **ដារី ចេតនា** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១៤. លោក **យង់ ស៊ី** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១៥. លោក **សុខ រដ្ឋ** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល | សមាជិក |
| ១៦. កញ្ញា **ទី លីម៉ី** | អនុប្រធានលេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ១៧. លោក **គន សេងហ៊ាន់** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល | សមាជិក |
| ១៨. លោក **ឌី សក្តិដែន** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ១៩. លោក **សំរិត ឧត្តម** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន | សមាជិក |
| ២០. លោក **ហា សុគន្ធ** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ២១. លោក **ខេន ចន្ថា** | ប្រធានការិយាល័យនៃមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ២២. កញ្ញា **ទួន វណ្ណា** | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ២៣. លោក **ផង់ កុសល់** | មន្ត្រីនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល | សមាជិក |
| ២៤. លោក **ហៀង សុយ៉ារ៉ូ** | មន្ត្រីជំនាញជាន់ខ្ពស់នៃ អ.គ.ហ. | សមាជិក |
| ២៥. លោក **លឹម សុខហេង** | មន្ត្រីជំនាញជាន់ខ្ពស់នៃ អ.គ.ហ. | សមាជិក |
| ២៦. លោក **តាន់ វណ្ណលិ** | មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ស.ធ.ឱ. | សមាជិក |
| ២៧. លោក **រិទ្ធ រតនៈ** | មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ស.ធ.ឱ. | សមាជិក |
| ២៨. កញ្ញា **លន់ ស្មើនីតា** | មន្ត្រីនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ២៩. កញ្ញា **លី ស៊ុយឡាង** | មន្ត្រីនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក។ |

**ប្រការ២-.**

ក្រុមការងាររៀបចំនិម្មាបនកម្មនិងគម្រោងបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការនិងផែនទីមគ្គុទេសក៍សម្រាប់តម្រង់ទិសដល់ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួមសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ
- រៀបចំនិម្មាបនកម្មនៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដែលជាផ្នែកមួយនៃប្រព័ន្ធអេកូឡូស៊ីឌីជីថលរួមរបស់ ក.ស.ហ.វ.
- រៀបចំក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យនិងក្របខ័ណ្ឌអន្តរប្រតិបត្តិការនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ
- ដឹកនាំសម្របសម្រួលការងាររៀបចំនិម្មាបនកម្មនិងផែនការសម្រាប់ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលគាំទ្រដល់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ
- សិក្សានិងវាយតម្លៃលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដែលដំណើរការឬកំពុងរៀបចំទាំងអស់នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- កៀរគរធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការងារអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួមសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ
- រៀបចំកិច្ចប្រជុំ សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីប្រមូលធាតុចូល ដកស្រង់បទពិសោធនិងឧត្តមានុវត្តន៍និងពិគ្រោះយោបល់ តាមការចាំបាច់
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក.ស.ហ.វ.
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានក្រុមការងារ។

**ប្រការ៣-.**

ក្រុមការងាររៀបចំនិម្មាបនកម្មនិងគម្រោងបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។ ក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់ ប្រធានក្រុមការងារអាចផ្ទេរសិទ្ធិជូនអនុប្រធានក្រុមការងារដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារឬអនុប្រធានក្រុមការងារក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់។ ប្រធានក្រុមការងារឬអនុប្រធានក្រុមការងារក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់ មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័ននិងអង្គភាពពាក់ព័ន្ធ ក៏ដូចជាវិស័យឯកជន ដើម្បីចូលរួមកិច្ចប្រជុំនិងពិគ្រោះយោបល់ តាមការចាំបាច់។

**ប្រការ៤-.**

ក្រុមការងាររៀបចំនិម្មាបនកម្មនិងគម្រោងបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ មានសិទ្ធិប្រើប្រាស់ត្រារបស់ ក.ស.ហ.វ. នៅក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

**ប្រការ៥-.**

ក្រុមការងាររៀបចំនិម្មាបនកម្មនិងគម្រោងបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ មានអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលនៃ ក.ស.ហ.វ. ជាលេខាធិការដ្ឋាន។ លេខាធិការដ្ឋានក្រុមការងារ បំពេញមុខងារជាសេនាធិការជូនក្រុមការងារនេះលើការងាររដ្ឋបាលនិងបច្ចេកទេស។

**ប្រការ៦-.**

ក្រុមការងាររៀបចំនិម្មាបនកម្មនិងគម្រោងបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និងលេខាធិការដ្ឋានក្រុមការងារនេះ អាចប្រើប្រាស់ថវិការង្វាន់របស់ ក.ស.ហ.វ. ឬថវិកាពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីគាំទ្រដល់ការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន តាមការសម្រេចរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក.ស.ហ.វ.។

**ប្រការ៧-.**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទ ក.ស.ហ.វ. ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ

រក្សាសិទ្ធិដោយ
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ